ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
# ឆ្នាំ២០២៣-២០២៨

រៀបចំដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ខែកញ្ញា ឆ្នាំ២០២៣

# អារម្ភកថា

ក្នុងរយៈពេលប្រមាណ២ទសវត្សរ៍ចុងក្រោយ មុនវិបត្តិនៃជំងឺកូវីដ-១៩ កម្ពុជាបានក្លាយជាប្រទេសមួយ ក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចរីកធំធាត់លឿនជាងគេក្នុងតំបន់និងលើសកលលោក ជាមួយនឹងអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមជាង៧%ក្នុងមួយឆ្នាំ។ សមិទ្ធផលនេះសម្រេចបានដោយការដាក់ចេញនិងការអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ព្រមទាំងកម្មវិធីកែទម្រង់នានា ជាបន្តបន្ទាប់ប្រកបដោយស្មារតីបុរេសកម្មនិងការទទួលខុសត្រូវខ្ពស់ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញពិពិធកម្មសេដ្ឋកិច្ច។ ជាមួយគ្នានេះ កម្ពុជាក៏ទទួលបានជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងការកាត់បន្ថយអត្រាភាពក្រីក្រនិងវិសមភាពសង្គម ព្រមទាំងការកាត់បន្ថយអត្រាមរណភាពមាតា ទារក និងកុមារនិងការធ្វើឱ្យប្រសើរឡើងនូវអាយុកាលមធ្យមរបស់ប្រជាជន តាមរយៈការយកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញការអភិវឌ្ឍវិស័យអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យសុខភាពសាធារណៈនិងអាហារូបត្ថម្ភ និងប្រព័ន្ធគាំពារសង្គម។ ក្រៅពីសមិទ្ធផលទាំងនេះ កិត្យានុភាពកម្ពុជានៅលើឆាកអន្តរជាតិនិងតំបន់ ក៏ត្រូវបានល្បីសុសសាយគួរជាទីមោទនៈផងដែរ ដែលការណ៍នេះឆ្លុះបញ្ចាំងតាមរយៈការចូលរួមចំណែកក្នុងការដឹកនាំកិច្ចការតំបន់និងសកល ដោយស្មើមុខស្មើមាត់ ដូចជាការធ្វើជាម្ចាស់ផ្ទះនៃ**កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១** និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ប្រកបដោយភាពជោគជ័យ នៅក្នុងឆ្នាំ២០២២ និងការធ្វើជាម្ចាស់ផ្ទះរៀបចំកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅក្នុងឆ្នាំ២០២៣ បន្ទាប់ពីការរង់ចាំអស់រយៈពេល៦៤ឆ្នាំ។

ទោះជាយ៉ាងនេះក្តី ក្នុងបរិការណ៍នៃការធ្លាក់ចុះនៃសន្ទុះកំណើនសេដ្ឋកិច្ចសកល ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ និងបញ្ហាប្រឈមសកលផ្សេងទៀត កម្ពុជាមានភាពចាំបាច់ក្នុងការពន្លឿនការអនុវត្តកិច្ចការកែទម្រង់ជារចនាសម្ព័ន្ធឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត និងស្វែងរកសក្តានុពលថ្មីៗ ដើម្បីស្តារនិងជំរុញកំណើនឱ្យងើបឡើងវិញ ត្រឡប់មកលើបន្ទាត់សក្តានុពល ជាពិសេស លើកកម្ពស់កិច្ចអភិវឌ្ឍសង្គមសេដ្ឋកិច្ច ប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់ទៅនឹងវិបត្តិ។ ក្នុងនោះ ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសក្តានុពលដ៏ធំសម្រាប់ការចូលរួមចំណែកលើកកម្ពស់ការអភិវឌ្ឍជាតិយើង។ តួយ៉ាង ប្រជាជនកម្ពុជាដែលប្រកបមុខរបរនិងធ្វើការងារ ភាគច្រើន គឺនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងមិនទាន់អាចចូលរួមចំណែកឱ្យបានពេញលេញក្នុងដំណើរការនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជានៅឡើយ ដោយផលិតភាពពលកម្មនិងប្រសិទ្ធភាពសេដ្ឋកិច្ចនៃសកម្មភាពទាំងនោះ នៅមានកម្រិតទាប។ ម្យ៉ាងវិញទៀត មេរៀនពីវិបត្តិនៃជំងឺកូវីដ-១៩ ក៏បានរំលេចឱ្យឃើញកាន់តែច្បាស់ពីភាពចាំបាច់ក្នុងការគិតគូរអំពីការដាក់ចេញវិធានការនិងកម្មវិធីគាំពារ ឱ្យកាន់តែគ្រប់ជ្រុងជ្រោយ សម្រាប់អ្នកប្រកបមុខរបរ និងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ ដោយក្រុមជនទាំងនេះជាប្រជាជនដែលងាយរងគ្រោះនិងទទួលផលប៉ះពាល់ធ្ងន់ធ្ងរក្នុងគ្រាមានវិបត្តិ។

ដោយមើលឃើញពីសក្តានុពលនិងបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលបានកំណត់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាអាទិភាពដ៏ចម្បងមួយ ក្នុងការចូលរួមជួយកែលម្អជីវភាពប្រជាជននិងជំរុញការស្តារកំណើនសេដ្ឋកិច្ចកម្ពុជាឡើងវិញ តាមរយៈការលើកកម្ពស់ការគាំពារនិងការពង្រឹងសមត្ថភាព ផលិតភាព និងភាពធន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងពន្លឿនការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីធានាឱ្យបាននូវភាពធន់ ភាពប៉ាន់ប្រមាណបាន និងភាពរីកចម្រើនទៅមុខនៃការធ្វើធុរកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងការប្រកបអាជីវកម្ម មុខរបរ និងការងារចិញ្ចឹមជីវិតនៅកម្ពុជា។

ក្នុងបរិការណ៍ពោរពេញដោយភាពមិនប្រាកដប្រជាខ្ពស់ កើតចេញពីការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ច ពាណិជ្ជកម្មសកល ទាំងពេលបច្ចុប្បន្ននិងទៅអនាគត ភាពជោគជ័យនៃការជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ នឹងក្លាយជាកាតាលីករមួយក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវ **«យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨»** ជាមួយនឹងចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យរីកធំធាត់និងមានលទ្ធភាពឈានចូលក្នុងប្រព័ន្ធ ហើយក្លាយទៅជាកម្លាំងចលករដ៏សំខាន់ ក្នុងការកែលម្អជីវភាពរបស់ប្រជាជន និងអាចរួមចំណែកជាអតិបរមាក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន ភាពរឹងមាំ និងភាពធន់ទៅនឹងវិបត្តិ។

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យនេះ ព្រមទាំងធានាប្រសិទ្ធភាពនិងភាពសមស្របនឹងបរិបទកម្ពុជា យុទ្ធសាស្ត្រជាតិនេះបានកំណត់អាទិភាពជាយុទ្ធសាស្ត្រចំនួន៥ រួមមាន: (១) ការកំណត់ ការកែសម្រួល និងការរៀបចំយន្តការបង្កលក្ខណៈងាយស្រួល ដើម្បីឈានចូលក្នុងប្រព័ន្ធ (២) ការកាត់បន្ថយបន្ទុកលើការបំពេញអនុលោមភាព (៣) ការផ្តល់ការគាំពារនិងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ (៤) ការលើកកម្ពស់សមត្ថភាពនិងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ និង (៥) ការពង្រឹងនិងពង្រីកការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងនិងការចូលរួម។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(គ.ស.ហ.)** ដែលបានដឹកនាំ តម្រង់ទិស និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស ក្រុមការងារអន្តរក្រសួង ក្នុងការរៀបចំយុទ្ធសាស្ត្រជាតិដ៏មានសារៈសំខាន់នេះ រហូតសម្រេចបានជោគជ័យ។ ទន្ទឹមនេះ ខ្ញុំក៏សូមលើកទឹកចិត្តឱ្យគ្រប់ក្រសួង ស្ថាប័ន វិស័យឯកជន សមាគម អង្គការជាតិនិងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍទាំងអស់ ផ្តល់កិច្ចសហការជិតស្និទ្ធ ប្រកបដោយស្មារតីស្ថាបនា ក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិនេះប្រកបដោយស្មារតីបុរេសកម្មនិងការទទួលខុសត្រូវខ្ពស់។

ជាចុងក្រោយ ខ្ញុំជឿជាក់យ៉ាងមុតមាំថា **«យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨»** នឹងក្លាយជាសក្ខីភាពដែលសបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់និងកិច្ចខិតខំប្រឹងប្រែងឥតស្រាកស្រាន្តរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការគាំទ្រ ពង្រឹងសមត្ថភាព និងបង្កើនផលិតភាពនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងពន្លឿនការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីបម្រើផលប្រយោជន៍ជាតិនិងប្រជាជនកម្ពុជាទាំងមូលឱ្យកាន់តែល្អប្រសើរឡើង។

*ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# បញ្ជីពាក្យកាត់

| | |
|---|---|
| ក.ក.ប. | ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.ឧ.វ.ប.ន. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| គ.ស.ហ. | គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ប.ស.ស. | បេឡាជាតិសន្តិសុខសង្គមនៃក.ក.ប. |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| អ.ព.ដ. | អគ្គនាយកដ្ឋានពន្ធដារនៃក.ស.ហ.វ. |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ( Cambodia Data Exchange ) |
| ILO | អង្គការអន្តរជាតិខាងការងារ ( International Labour Organization ) |
| MSEs | សហគ្រាសធុនមីក្រូនិងតូច ( Micro and Small Enterprises ) |
| MSMEs | សហគ្រាសធុនមីក្រូ តូច និងមធ្យម ( Micro, Small and Medium Enterprises ) |
| TVET | កម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ( Technical and Vocational Education and Training ) |

# មាតិកា

**អារម្ភកថា** ............ i
**បញ្ជីពាក្យកាត់** ............ iii
**មាតិកា** ............ iv
**ផ្នែកទី១ សេចក្តីផ្តើម** ............ ១
១.១- និន្នាការតំបន់និងសកល ............ ១
១.២- ទស្សនាទាននៃការរៀបចំយុទ្ធសាស្ត្រជាតិ ............ ២
**ផ្នែកទី២ ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រជាតិ** ............ ៤
២.១- ចក្ខុវិស័យ ............ ៤
២.២- គោលបំណងនិងគោលដៅ ............ ៤
២.៣- អភិក្រម ............ ៥
**ផ្នែកទី៣ ស្ថានភាពនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា** ............ ៨
៣.១- លក្ខណៈនៃប្រជាជន នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៃប្រទេសកម្ពុជា ............ ៨
៣.២- អ្នកប្រកបមុខរបរនិងធ្វើការងារ និងសហគ្រាស នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ............ ៩
**ផ្នែកទី៤ បញ្ហាប្រឈមនិងកិច្ចអន្តរាគមន៍** ............ ១៣
៤.១- បញ្ហាប្រឈម ............ ១៣
៤.២- កិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាល ............ ១៥
**ផ្នែកទី៥ អាទិភាពជាយុទ្ធសាស្ត្រ** ............ ១៨
៥.១- ការកំណត់ ការកែសម្រួល និងការរៀបចំយន្តការបង្កលក្ខណៈងាយស្រួល ដើម្បីឈានចូលក្នុងប្រព័ន្ធ ............ ២០
៥.២- ការកាត់បន្ថយបន្ទុកលើការបំពេញអនុលោមភាព ............ ២០
៥.៣- ការផ្តល់ការគាំពារនិងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ ............ ២១
៥.៤- ការលើកកម្ពស់សមត្ថភាព និងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ ............ ២២
៥.៥- ការពង្រឹងនិងពង្រីកការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងនិងការចូលរួម ............ ២២
**ផ្នែកទី៦ ការគ្រប់គ្រងហានិភ័យ** ............ ២៣
**ផ្នែកទី៧ យន្តការស្ថាប័ន និងការតាមដាននិងវាយតម្លៃ** ............ ២៥
**ផ្នែកទី៨ សេចក្តីសន្និដ្ឋាន** ............ ២៦
**ឧបសម្ព័ន្ធទី១ ការកំណត់វិសាលភាពនិងការធ្វើអាទិភាពូបនីយកម្ម** ............ ២៨
**ឧបសម្ព័ន្ធទី២ ការកំណត់និយមន័យ** ............ ៣០
**ឧបសម្ព័ន្ធទី៣ តារាងផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨** ............ ៣២

# ផ្នែកទី១
# សេចក្តីផ្តើម

## ១.១- និន្នាការតំបន់និងសកល

សេដ្ឋកិច្ចក្រៅប្រព័ន្ធ (Informal Economy) បាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតអាជីវកម្ម មុខរបរ និងការងារ និងជាប្រភពចំណូលដ៏ចម្បងរបស់ប្រជាជនជាច្រើននៅតាមបណ្តាប្រទេសនៅលើសកលលោក ជាពិសេសប្រទេសកំពុងអភិវឌ្ឍ។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកក្នុងឆ្នាំ២០២២ សេដ្ឋកិច្ចក្រៅប្រព័ន្ធគ្របដណ្តប់ប្រមាណ២០%នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) និងប្រមាណ១៦%នៃការងារសរុបនៅក្នុងប្រទេសអភិវឌ្ឍ និងគ្របដណ្តប់ជាមធ្យមជិត ៣២% នៃផ.ស.ស. និង៧០%នៃការងារសរុបនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់និងកំពុងអភិវឌ្ឍ (Emerging and Developing Countries)។

ការសិក្សាមួយចំនួនបានបង្ហាញថានៅពេលប្រទេសមានការរីកចម្រើន សេដ្ឋកិច្ចក្រៅប្រព័ន្ធនឹងវិវត្តរួមតូចបន្តិចម្តងៗ ដោយធុរជននិងកម្មករ និយោជិត នឹងធ្វើអន្តរកាល (Transition) ដោយស្វ័យប្រវត្តិ ចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ជាក់ស្តែង របាយការណ៍របស់ធនាគារពិភពលោកក្នុងឆ្នាំ២០២២ បានប៉ាន់ស្មានថា ពីឆ្នាំ១៩៩០ដល់ឆ្នាំ២០១៨ ការចូលរួមរបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងសេដ្ឋកិច្ច បានធ្លាក់ចុះជាមធ្យម៧%ក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់និងកំពុងអភិវឌ្ឍ (ពី៣៨,៩% នៃផ.ស.ស. ក្នុងឆ្នាំ១៩៩០ មកជិត៣២%នៃផ.ស.ស.ក្នុងឆ្នាំ២០១៨)។

ទោះជាយ៉ាងណាក្តី សេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតែរួមចំណែកធំ នៅក្នុងសេដ្ឋកិច្ច ហើយការធ្វើអន្តរកាលមានសន្ទុះយឺតជាងការរំពឹងទុក។ ជាមួយគ្នានេះ វិបត្តិផ្សេងៗ ជាពិសេសវិបត្តិនៃជំងឺកូវីដ-១៩ ក៏បានបង្ហាញឱ្យឃើញថា ទំហំដ៏ធំនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចបង្កឱ្យមានការរាំងស្ទះដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងជះឥទ្ធិពលអវិជ្ជមានដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយវិសមភាពសង្គមនិងការអភិវឌ្ឍធនធានមនុស្ស។ ជាក់ស្តែង ក្នុងកំឡុងពេលនៃវិបត្តិនៃជំងឺកូវីដ-១៩ អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅប្រទេសជាច្រើន បូករួមទាំងកម្ពុជា បានទទួលរងផលប៉ះពាល់ខ្លាំង ខណៈដែលប្រសិទ្ធភាពនៃវិធានការអន្តរាគមន៍ផ្សេងៗនៅមានកម្រិត ដោយសារការលំបាកក្នុងការកំណត់និងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ផ្អែកលើបទពិសោធជាក់ស្តែងទាំងនេះ បច្ចុប្បន្ន ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានក្លាយជារបៀបវារៈគោលនយោបាយដ៏សំខាន់មួយ ក្នុងការចូលរួមស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ និងការឈានឆ្ពោះទៅរកការសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់។ ជាងនេះទៅទៀត ក្នុងបរិការណ៍នៃការអភិវឌ្ឍបច្ចុប្បន្ននិងអនាគត ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ នឹងចូលរួមចំណែកដោះស្រាយនូវផលប៉ះពាល់ដែលជាស្លាកស្នាមបន្សល់ទុកពីវិបត្តិនៃជំងឺកូវីដ-១៩ ជាពិសេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍ និងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ ដូចជាគម្លាតឌីជីថល ដែលកើតចេញពីបរិវត្តកម្មឌីជីថល និងបាននិងកំពុងបង្កើតកាលានុវត្តភាពថ្មីសម្រាប់ការជំរុញសម្ទុះនៃការអភិវឌ្ឍឱ្យកាន់តែខ្លាំងឡើង។

យោងតាមឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធបាន ប្រកបដោយប្រសិទ្ធភាព ប្រទេសនីមួយៗត្រូវផ្តោតលើការជំរុញការធ្វើអន្តរកាលចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ នេះម្យ៉ាង និងម្យ៉ាងទៀត ត្រូវផ្តោតជាសំខាន់លើការការពារកុំឱ្យសកម្មភាពនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ធ្លាក់ចូលទៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការទ្រទ្រង់ការបង្កើតអាជីវកម្ម មុខរបរ និងការងារ ឱ្យមានស្ថិរភាព ផលិតភាពខ្ពស់ ប្រាក់ចំណូលសមរម្យ ព្រមទាំងផ្តល់ការការពារសិទ្ធិនិងកិច្ចគាំពារសង្គមចាំបាច់នានា តាមបរិបទនៃកម្រិតអភិវឌ្ឍប្រទេសនីមួយៗ។ អាស្រ័យហេតុនេះ ការគិតគូរនិងការរៀបចំការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវមានទម្រង់ជាយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែង ដែលមានសមាសភាគច្រើនរួមបញ្ចូលគ្នាប្រទាក់ក្រឡាគ្នា និងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ សមាសភាគសំខាន់ៗនៃយុទ្ធសាស្ត្រ មានដូចជាការបង្កលក្ខណៈងាយស្រួលដល់ការឈានចូលក្នុងប្រព័ន្ធ ការផ្តល់ផលប្រយោជន៍ឬការលើកទឹកចិត្ត ដើម្បីឱ្យឈានចូលក្នុងប្រព័ន្ធ និងការលើកកម្ពស់ការយល់ដឹងនិងថែបំប៉នឱ្យរីកធំធាត់ ជាដើម។

## ១.២- ទស្សនាទាននៃការរៀបចំយុទ្ធសាស្ត្រជាតិ

សេដ្ឋកិច្ចកម្ពុជាមានអត្រាកំណើនជាមធ្យម៧%ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយ មុនវិបត្តិនៃជំងឺកូវីដ-១៩។ កំណើនដ៏ខ្ពស់នេះបានជួយកាត់បន្ថយអត្រាភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាគួរឱ្យកត់សម្គាល់ ព្រមទាំងបានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសស្មើមុខស្មើមាត់ ជាមួយបណ្តាប្រទេសជិតខាងក្នុងតំបន់និងលើសកលលោក។ ជាងនេះទៅទៀត ក្នុងកំឡុងពេលនៃវិបត្តិនៃជំងឺកូវីដ-១៩ កម្ពុជាបានក្លាយជាប្រទេសឈានមុខមួយក្នុងតំបន់និងលើសកលលោក ដែលអាច

គ្រប់គ្រងជំងឺនេះបានយ៉ាងល្អប្រសើរ អាចបើកដំណើរការប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ ព្រមទាំងអាចស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញបានយ៉ាងឆាប់រហ័ស។ ជាក់ស្តែង វិបត្តិនៃជំងឺកូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមានជាលើកដំបូងក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយ ជាមួយនឹងអត្រាកំណើន-៣,១%នៅក្នុងឆ្នាំ២០២០ ប៉ុន្តែសេដ្ឋកិច្ចកម្ពុជាអាចងើបចេញពីវិបត្តិបានយ៉ាងឆាប់រហ័ស ដោយសម្រេចបានអត្រាកំណើន៣%នៅក្នុងឆ្នាំ២០២១ និង៥,២%នៅក្នុងឆ្នាំ២០២២។

ទោះជាយ៉ាងនេះក្តី កម្ពុជាមានភាពចាំបាច់ក្នុងការជំរុញការអនុវត្តកិច្ចការកែទម្រង់ជារចនាសម្ព័ន្ធឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត និងស្វែងរកសក្តានុពលថ្មីៗដើម្បីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឱ្យងើបឡើងវិញ ជាពិសេស ឱ្យស្ថិតនៅលើបន្ទាត់សក្តានុពលប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់ទៅនឹងវិបត្តិ។ ក្នុងនោះ ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសក្តានុពលដ៏ធំសម្រាប់ការចូលរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយកម្ពុជានៅមានលទ្ធភាពខ្ពស់ក្នុងការចាប់យកកាលានុវត្តភាព និងទាញយកអត្ថប្រយោជន៍ជាអតិបរមាពីសក្តានុពលនៃកម្លាំងពលកម្មនិងសកម្មភាពអាជីវកម្មនៅក្នុងសេដ្ឋកិច្ច ក្រៅប្រព័ន្ធ។ បន្ថែមលើនេះ បទពិសោធផ្ទាល់របស់កម្ពុជាក្នុងកំឡុងពេលនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក៏បានបង្ហាញឱ្យឃើញថា សេដ្ឋកិច្ចក្រៅប្រព័ន្ធអាចក្លាយជាហានិភ័យចម្បងមួយក្នុងពេលមានវិបត្តិ ដោយរាជរដ្ឋាភិបាលបានជួបប្រទះនឹងការលំបាកក្នុងការកំណត់អត្តសញ្ញាណ និងផ្តល់ការគាំទ្រដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ក្នុងស្មារតីនេះ កម្ពុជាត្រូវបង្កើនការយកចិត្តទុកដាក់ទ្វេដងលើការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីពង្រឹងសមត្ថភាព ភាពធន់ និងភាពប្រកួតប្រជែងរបស់វិស័យឯកជន និងប្រជាជនទូទៅ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធផង និងចាប់យកសក្តានុពលនេះឱ្យបានជាអតិបរមាក្នុងការឈានឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យប្រែក្លាយកម្ពុជា ឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ផង។

ជាមួយនឹងស្មារតីខាងលើនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាបន្តបន្ទាប់ ដែលបានគាំទ្រដោយផ្ទាល់និងដោយប្រយោលដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាការរៀបចំការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ការលើកទឹកចិត្តផ្នែកពន្ធដារ ការពង្រីកវិសាលភាពនៃកម្មវិធីជំនួយសង្គម និងការផ្តល់ការបណ្តុះបណ្តាលជំនាញ ជាដើម។ ដើម្បីបំពេញបន្ថែមឱ្យបានពេញលេញ គ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡា

រាជរដ្ឋាភិបាលកម្ពុជាសម្រេចរៀបចំនិងដាក់ឱ្យអនុវត្តនូវ «**យុទ្ធសាស្ត្រជាតិ ស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨**» សំដៅផ្ដល់ការគាំពារ និងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងពង្រឹងសមត្ថភាពឱ្យអាចចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីអាចទទួលបានការគាំទ្រពីរាជរដ្ឋាភិបាល និងអាចចូលរួមក្នុងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យអស់សក្ដានុពល។

# ផ្នែកទី២
# ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រជាតិ

## ២.១- ចក្ខុវិស័យ

ជំងឺកូវីដ-១៩និងបញ្ហាប្រឈមផ្សេងទៀត ដែលបាននិងកំពុងកើតមានឡើងជាបន្តបន្ទាប់ បាន និងកំពុងដាក់សម្ពាធឥតឈប់ឈរមកលើសុខុមាលភាពនិងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ពិសេសអ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមទាំងនេះ និងឆ្លើយតបទៅនឹងបញ្ហាប្រឈមនិងស្ថានភាពជាក់ស្ដែងនៅកម្ពុជា ព្រមទាំងចាប់យកកាលានុវត្តភាព និងសក្ដានុពលថ្មី(Untapped Potential) ដែលអាចលេចចេញពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ រាជរដ្ឋាភិបាលកម្ពុជា សម្រេចដាក់ចេញនូវ «**យុទ្ធសាស្ត្រជាតិ ស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨**» ជាមួយនឹងចក្ខុវិស័យ **អភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យរីកធំធាត់និងមានលទ្ធភាពឈានចូលក្នុងប្រព័ន្ធ ហើយក្លាយទៅជាកម្លាំងចលករដ៏សំខាន់ក្នុងការកែលម្អជីវភាពរបស់ប្រជាជន និងអាចរួមចំណែកជាអតិបរមាក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន ភាពរឹងមាំ និងភាពធន់ទៅនឹងវិបត្តិ។**

## ២.២- គោលបំណងនិងគោលដៅ

ស្របតាមចក្ខុវិស័យខាងលើ យុទ្ធសាស្ត្រជាតិនេះមានគោលបំណង**លើកកម្ពស់ការគាំពារនិងការពង្រឹងសមត្ថភាព ផលិតភាព និងភាពធន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងជំរុញនិងពន្លឿនការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីធានាឱ្យបាននូវភាពធន់ភាពប៉ាន់ប្រមាណបាន និងភាពរីកចម្រើនទៅមុខនៃការធ្វើធុរកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងការប្រកបអាជីវកម្ម មុខរបរ និងការងារចិញ្ចឹមជីវិតនៅកម្ពុជា។**

ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ស្របតាមចក្ខុវិស័យនិងគោលបំណងខាងលើ យុទ្ធសាស្ត្រជាតិនេះ ដាក់ចេញនូវគោលដៅចំនួន៤សំខាន់ៗ ដូចខាងក្រោម៖

**ទី១** បង្កលក្ខណៈងាយស្រួលដល់ការឈានចូលក្នុងតំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬនិយាយម្យ៉ាងទៀត ឈានចូលក្នុងប្រព័ន្ធអភិវឌ្ឍន៍អន្តរកាលមួយ ( Into the System ) មុននឹងអាចចូលរួមបានពេញលេញក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

**ទី២** ផ្តល់ប្រយោជន៍ដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ ដើម្បីជានាថា មិនធ្លាក់ចូលទៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធវិញ ទោះបីក្នុងករណីមិនអាចចូលរួមពេញលេញក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ក៏ដោយ។

**ទី៣** ថែបំប៉នអ្នកដែលបានឈានចូលក្នុងប្រព័ន្ធ ឱ្យរីកធំធាត់ ដើម្បីអាចចូលរួមពេញលេញក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

**ទី៤** លើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងអត្ថប្រយោជន៍នៃការឈានចូលក្នុងប្រព័ន្ធ ក៏ដូចជាការលើកកម្ពស់ការចូលរួមរបស់គ្រប់តួអង្គពាក់ព័ន្ធ។

## ២.៣- អភិក្រម

ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រជាតិនេះ ត្រូវអនុលោមតាមអភិក្រមសំខាន់ៗ ដែលមានភាពប្រទាក់ក្រឡាគ្នា ដូចខាងក្រោម៖

**ទី១** **កំណត់វិសាលភាព និងការធ្វើអាទិភាវូបនីយកម្ម** ពិសេសការកំណត់វិស័យ និងប្រភេទអាជីវកម្ម មុខរបរ និងការងារអាទិភាព ដើម្បីអាចឆ្លើយតបទៅនឹងភាពមានកម្រិតនៃធនធានរបស់រាជរដ្ឋាភិបាល និងទំហំដ៏ធំនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ( ឧបសម្ព័ន្ធទី១នៃយុទ្ធសាស្ត្រជាតិនេះ )។

**ទី២** មានភាពទន់ភ្លន់និងបត់បែន **ដោយផ្តោតការយកចិត្តទុកដាក់លើមនុស្សក្នុងរយៈពេលខ្លី** តាមរយៈការផ្តល់កិច្ចគាំពារសង្គម និងការពង្រឹងសមត្ថភាព និងផលិតភាព ដែលប្រៀបបាននឹងការទាក់ទាញឱ្យចូលរួមទៅក្នុងប្រព័ន្ធ ( System ) ដែលមានស្រាប់ ( ដូចជាមូលនិធិសមធម៌សុខាភិបាល និងការបណ្តុះបណ្តាលជំនាញ ជាដើម) មុននឹងអាចចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ឱ្យបានពេញសក្តានុពល។

**ទី៣ ជំរុញការធ្វើអន្តរកាលពីសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅសេដ្ឋកិច្ចក្នុងប្រព័ន្ធ សម្រាប់រយៈពេលមធ្យម និងវែង** ដើម្បីកាត់បន្ថយបន្តិចម្តងៗនូវទំហំនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បង្កើនការគាំពារដែលផ្អែកលើភាគទាន (Contribution-Based) ព្រមទាំងបង្កើនចំណូលនិងការចូលរួមចំណែក ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

**ទី៤ កំណត់និយមន័យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យបានច្បាស់លាស់** ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ (ឧបសម្ព័ន្ធទី២នៃយុទ្ធសាស្ត្រជាតិនេះ)។

## រូបភាពទី១: ក្របខ័ណ្ឌរួមនៃយុទ្ធសាស្ត្រជាតិ ស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨

### ចក្ខុវិស័យ

អភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យរីកធំធាត់និងមានលទ្ធភាពឈានចូលក្នុងប្រព័ន្ធ ហើយក្លាយទៅជាកម្លាំងចលករដ៏សំខាន់ក្នុងការកែលម្អជីវភាពរបស់ប្រជាជន និងអាចរួមចំណែកជាអតិបរមាក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន ភាពរឹងមាំ និងភាពធន់ទៅនឹងវិបត្តិ

### គោលបំណង

លើកកម្ពស់ការគាំពារនិងការពង្រឹងសមត្ថភាព ផលិតភាព និងភាពធន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងជំរុញនិងពន្លឿនការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីធានាឱ្យបាននូវភាពធន់ ភាពប៉ាន់ប្រមាណបាន និងភាពរីកចម្រើនទៅមុខនៃការធ្វើធុរកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និង ការប្រកបអាជីវកម្ម មុខរបរ និងការងារចិញ្ចឹមជីវិតនៅកម្ពុជា

### គោលដៅ

- បង្កលក្ខណៈងាយស្រួលដល់ការឈានចូលក្នុងតំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬនិយាយម្យ៉ាងទៀត ឈានចូលក្នុងប្រព័ន្ធអភិវឌ្ឍន៍អន្តរកាលមួយ (Into the System) មុននឹងអាចចូលរួមបានពេញលេញក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ
- ផ្ដល់ប្រយោជន៍ដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ ដើម្បីធានាថាមិនធ្លាក់ចូលទៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធវិញ ទោះបីក្នុងករណីមិនអាចចូលរួមពេញលេញក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធក៏ដោយ
- ថែបំប៉នអ្នកដែលបានឈានចូលក្នុងប្រព័ន្ធឱ្យរីកធំធាត់ ដើម្បីអាចចូលរួមពេញលេញក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ
- លើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងអត្ថប្រយោជន៍នៃការឈានចូលក្នុងប្រព័ន្ធ ក៏ដូចជាការលើកកម្ពស់ការចូលរួមរបស់គ្រប់តួអង្គពាក់ព័ន្ធ

### អាទិភាពយុទ្ធសាស្ត្រ

- ការកំណត់ការកែសម្រួល និងការរៀបចំយន្តការបង្កលក្ខណៈងាយស្រួល ដើម្បីឈានចូលក្នុងប្រព័ន្ធ
- ការកាត់បន្ថយបន្ទុកលើការបំពេញអនុលោមភាព
- ការផ្ដល់ការគាំពារ និងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ
- ការលើកកម្ពស់សមត្ថភាព និងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ
- ការពង្រឹងនិងពង្រីកការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងនិងការចូលរួម

# ផ្នែកទី៣
# ស្ថានភាពនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា

សេដ្ឋកិច្ចក្រៅប្រព័ន្ធដើរតួនាទីយ៉ាងសំខាន់ ទាំងក្នុងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍ។ ការប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាប្រភពចំណូលដ៏សំខាន់របស់ប្រជាជន ដោយការចាប់ផ្ដើមសកម្មភាពអាជីវកម្ម មុខរបរ និងការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវការថ្លៃដើមទាប។ ទោះជាយ៉ាងណាក្ដី សេដ្ឋកិច្ចក្រៅប្រព័ន្ធមានទំហំធំ ស្មុគស្មាញ និងពាក់ព័ន្ធនឹងតួអង្គច្រើន ដែលការណ៍នេះបង្កឱ្យមានការលំបាកសម្រាប់រាជរដ្ឋាភិបាល ក្នុងការកំណត់អត្តសញ្ញាណ ដើម្បីគ្រប់គ្រងនិងគាំពារសំដៅលើកកម្ពស់កម្រិតជីវភាពព្រមទាំងការចូលរួមរបស់ប្រជាជនទៅក្នុងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ជាមួយនឹងសារៈសំខាន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប្រទេសនីមួយៗត្រូវយកចិត្តទុកដាក់លើការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដោយមានការស្វែងយល់ឱ្យបានស៊ីជម្រៅ អំពីការកំណត់តួអង្គនិងវិស័យអាទិភាពសំខាន់ៗ ដើម្បីអាចដាក់ចេញនូវផែនការសកម្មភាពមុតស្រួច ចំៗ និងប្រកបដោយប្រសិទ្ធភាព។

## ៣.១- លក្ខណៈនៃប្រជាជន នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៃប្រទេសកម្ពុជា

អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា មានចំនួនច្រើន និងស្ថិតនៅក្នុងវិស័យជាច្រើន ដូចជាវិស័យដឹកជញ្ជូន សេវាកម្ម លក់ដុំ លក់រាយ សិប្បកម្ម និងកសិកម្ម ជាដើម។ យោងតាមរបាយការណ៍នៃការសិក្សា និងការពិគ្រោះយោបល់ផ្ទាល់ជាមួយប្រជាជនគោលដៅនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងតំណាងសមាគម អង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍ អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ភាគច្រើន គឺជាកម្មករ និយោជិត ឬបុគ្គលស្វ័យនិយោជន៍ ដែលមានលក្ខណៈដូចខាងក្រោម៖

- មានប្រាក់ចំណូលទាបនិងមិនទៀងទាត់ ដែលអាចប្រើប្រាស់បានត្រឹមជីវភាពប្រចាំថ្ងៃ ទោះបី ជាត្រូវធ្វើការច្រើនម៉ោង ក៏ដោយ
- ប្រកបអាជីវកម្មឬមុខរបរដែលមានលក្ខណៈគ្រួសារ ឬប្រកបការងារមិនជាប់លាប់ (ម្ដងម្កាល ឬតាមរដូវ)

- ប្រកបអាជីវកម្ម មុខរបរ និង/ឬការងារច្រើន ក្នុងពេលតែមួយ ដើម្បីទ្រទ្រង់និងរក្សាលំនឹងជីវភាពគ្រួសារ ហើយងាយផ្លាស់ប្តូរអាជីវកម្ម មុខរបរ និងការងារ ពីមួយទៅមួយ ដែលការណ៍នេះបានធ្វើឱ្យសហគ្រាសជាច្រើន ជាពិសេសនៅក្នុងវិស័យសេវាកម្ម ដែលត្រូវការជំនាញទាប ជួបប្រទះនឹងបញ្ហាការផ្លាស់ប្តូរបុគ្គលិក(Turnover) ខ្ពស់
- មានតម្រូវការផ្នែកថែទាំសុខភាពខ្ពស់ ដោយសារការប្រកបអាជីវកម្ម មុខរបរ និង/ឬការងារ ត្រូវប្រឈមនឹងហានិភ័យការងារផ្នែកសុខភាពនិងសុវត្ថិភាពខ្ពស់ ប៉ុន្តែបញ្ហាជីវភាពប្រចាំថ្ងៃ បូករួមទាំងកង្វះការយល់ដឹងនិងចំណេះដឹង ធ្វើឱ្យអ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនសូវខ្វល់ខ្វាយច្រើនអំពីការគិតគូររយៈពេលវែង ពិសេសការឆ្លើយតបទៅនឹងជំងឺ របួស ឬពិការភាព ដែលអាចកើតមានឡើងជាយថាហេតុ និង
- មានជំនាញទាប ប៉ុន្តែបញ្ហាជីវភាពប្រចាំថ្ងៃនិងបញ្ហាចម្ងាយ អាចបង្កឱ្យមានការលំបាកក្នុងការទៅទទួលការបណ្តុះបណ្តាលជំនាញ។

ជារួម អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា មានលទ្ធភាពទាប ទាំងក្នុងទិដ្ឋភាពចំណូល ចំណេះដឹង ការយល់ដឹង និងជំនាញ។ ក្នុងន័យនេះ **ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់កម្ពុជា មិនអាចផ្តោតតែលើការជំរុញការចុះបញ្ជីចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងការពង្រឹងការបំពេញអនុលោមភាពតែមួយមុខទេ តែក៏ត្រូវមានការគិតគូរផងដែរលើការលើកកម្ពស់ ការគាំពារ ការគាំទ្រ និងការពង្រឹងសមត្ថភាព និងលទ្ធភាពរបស់អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។**

## ៣.២- អ្នកប្រកបមុខរបរនិងធ្វើការងារ និងសហគ្រាស នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

### ៣.២.១- អ្នកប្រកបមុខរបរនិងធ្វើការងារ

នៅកម្ពុជា ប្រជាជនមានការងារធ្វើ(Employed Population) មានចំនួនសរុបជិត៧,៩លាននាក់ (យោងតាមអង្កេតកម្លាំងពលកម្ម ឆ្នាំ២០១៩)។ ក្នុងនោះ ប្រជាជនមានការងារធ្វើនៅក្នុងវិស័យក្នុងប្រព័ន្ធ(Formal Sector) មានចំនួនជិត១,៧លាននាក់ ឬ ២១,៥%នៃប្រជាជនមានការងារធ្វើសរុប។ ដោយឡែក ប្រជាជនមានការងារធ្វើជិត៦,២លាននាក់ផ្សេងទៀត ធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ(Informal Sector)។

ប្រជាជនមានការងារធ្វើ អាចចែកចេញជា៤ក្រុមសំខាន់ៗរួមមាន: កម្មករ និយោជិត និយោជក អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន[១] និងអ្នកធ្វើការឱ្យគ្រួសារ ដោយមិនយកប្រាក់ឈ្នួល។ កម្មករ និយោជិត និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន មានចំនួនច្រើនជាងគេ និងគ្របដណ្តប់រហូតដល់ទៅ៤៧,៨%និង៣៦,៩% រៀងគ្នា នៃចំនួនប្រជាជនមានការងារធ្វើក្នុងឆ្នាំ២០១៩។ ក្នុងន័យនេះ **ការគិតគូរលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវផ្តោតលើក្រុមគោលដៅចំនួន២រួមមាន: (១) កម្មករ និយោជិត និង(២) អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន។**

- **កម្មករ និយោជិត** ភាគច្រើនធ្វើការក្នុងវិស័យកម្មន្តសាល សំណង់ កសិកម្ម ក៏ដូចជាវិស័យ ទេសចរណ៍ និងលក់ដុំ លក់រាយ ដែលអាចចែកចេញជា២ក្រុមសំខាន់ៗគឺ (១) កម្មករ និយោជិត ដែលធ្វើការក្នុងសហគ្រាស ដែលមិនទាន់បានចុះបញ្ជីឬស្នើសុំអាជ្ញាបណ្ណ ឬ លិខិតអនុញ្ញាតផ្សេងៗ និង (២) កម្មករ និយោជិតដែលធ្វើការក្នុងសហគ្រាស ដែលបានចុះបញ្ជី ឬស្នើសុំអាជ្ញាបណ្ណឬលិខិតអនុញ្ញាតផ្សេងៗ។
- **អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន** ភាគច្រើន ធ្វើការក្នុងវិស័យលក់រាយ ជួសជុល កសិកម្ម ដឹកជញ្ជូន ទេសចរណ៍ និងសេវាកម្មផ្សេងទៀត ដែលអាចបែងចែកជា២ក្រុមដែរគឺ (១) ប្រជាជនដែលប្រកបអាជីវកម្មឬមុខរបរ ដោយមានទីតាំងជាក់លាក់ និង(២) ប្រជាជនដែលប្រកបអាជីវកម្មឬមុខរបរ ដោយមិនមានទីតាំងជាក់លាក់ ឬប្រកបមុខរបរផ្ទាល់ខ្លួន ដូចជាអ្នកលក់ចល័តតាមដងផ្លូវ អ្នករត់ម៉ូតូឌុប អ្នករត់ម៉ូតូកង់បី អ្នកដឹកជញ្ជូន និងអ្នកប្រកបមុខរបរផ្សេងទៀតដែលមិនមែនលក់ដូរ ជាដើម។

### ៣.២.២- អង្គភាពសេដ្ឋកិច្ចឬសហគ្រាស

សេដ្ឋកិច្ចក្រៅប្រព័ន្ធគ្របដណ្តប់ទាំងលើកម្លាំងពលកម្ម ទាំងលើសហគ្រាស។ សេដ្ឋកិច្ចក្រៅប្រព័ន្ធមានទំហំធំនៅក្នុងប្រទេស ដែលមានសហគ្រាសតូចៗច្រើន ដោយសារសហគ្រាសតូចៗមានលទ្ធភាពទាប ក្នុងការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ក្នុងន័យនេះ ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ត្រូវមានការគិតគូរជាចាំបាច់នូវការលើកស្ទួយសហគ្រាសដែលនៅក្រៅប្រព័ន្ធ ឱ្យចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធដើម្បី

---

[១] យោងតាមអង្កេតកម្លាំងពលកម្ម អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន សំដៅដល់មនុស្សម្នាក់ដែលធ្វើការដោយទុនផ្ទាល់ខ្លួនជាមួយដៃគូម្នាក់ឬច្រើននាក់ នៅក្នុង "ការងារធ្វើដោយខ្លួនឯង" (Self-Employed Jobs) ដោយគ្មាននិយោជិតណាមួយចូលរួមការងារជាប្រចាំ ប៉ុន្តែក៏អាចជាមួយអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួលម្នាក់ឬច្រើននាក់ចូលរួមការងារម្តងម្កាល។

អាចទទួលបានការគាំទ្រផ្សេងៗ ដូចជាការផ្ដល់ការបណ្ដុះបណ្ដាលជំនាញ និងលទ្ធភាពទទួលបានហិរញ្ញប្បទាន ជាដើម។

នៅកម្ពុជា អង្គភាពសេដ្ឋកិច្ច (ដែលភាគច្រើនជាសហគ្រាសឯកជន) មានចំនួនសរុបជាង៥០ម៉ឺន នៅក្នុងឆ្នាំ២០១១ និងបានកើនឡើងទៅដល់ជាង៧៥ម៉ឺននៅក្នុងឆ្នាំ២០២២។ ក្នុងនោះ អង្គភាពសេដ្ឋកិច្ច ដែលនៅក្នុងប្រព័ន្ធ (បានចុះបញ្ជី ឬមានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត) បានកើនឡើងពី៣,៤%នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុបក្នុងឆ្នាំ២០១១ ទៅ១២,៤%នៃអង្គភាពសេដ្ឋកិច្ចសរុបក្នុងឆ្នាំ២០២២។

ក្នុងចន្លោះឆ្នាំ២០១១និង២០២២ គ្រប់ប្រភេទនៃអង្គភាពសេដ្ឋកិច្ច បានបង្ហាញអំពីនិន្នាការនៃការធ្វើអន្តរកាលចូលទៅក្នុងប្រព័ន្ធ (តារាងទី១ខាងក្រោម)។ ក្នុងនោះ អង្គភាពសេដ្ឋកិច្ចដែលមានចំនួនអ្នកធ្វើការចាប់ពី១០នាក់ឡើងទៅ (រាប់ទាំងកម្មករនិយោជិត និងនិយោជក) ស្ទើរតែ១០០%បានចូលទៅក្នុងប្រព័ន្ធក្នុងឆ្នាំ២០២២ ខណៈដែលអង្គភាពសេដ្ឋកិច្ចដែលមានចំនួនអ្នកធ្វើការចាប់ពី៥ទៅដល់៩នាក់ ដែលបានចូលរួមទៅក្នុងប្រព័ន្ធ បានកើនឡើងពី១៤%ក្នុងឆ្នាំ២០១១ ទៅដល់៨៣,៧%ក្នុងឆ្នាំ២០២២។ គួរបញ្ជាក់ថា អង្គភាពសេដ្ឋកិច្ចទាំងនេះមានចំនួនសរុបជាង៥ម៉ឺនដែលគ្រប់ដណ្ដប់ប្រហែល៧%ប៉ុណ្ណោះ នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុបជាង៧៥ម៉ឺនក្នុងឆ្នាំ២០២២។

ដោយឡែក អង្គភាពសេដ្ឋកិច្ចដែលមានចំនួនអ្នកធ្វើការតិចជាងឬស្មើ៤នាក់ គ្របដណ្ដប់រហូតដល់ទៅជាង៩២%នៃចំនួនអង្គភាពសេដ្ឋកិច្ចសរុប។ ក្នុងនោះ អង្គភាពសេដ្ឋកិច្ចដែលបានចូលរួមទៅក្នុងប្រព័ន្ធ បានកើនឡើងក្នុងកម្រិតតិចតួចពី១,៩%ក្នុងឆ្នាំ២០១១ ទៅ៦,៥%ក្នុងឆ្នាំ២០២២។

**តារាងទី១: ទំហំនៃអង្គភាពសេដ្ឋកិច្ចឬសហគ្រាស ដែលបានចូលរួមទៅក្នុងប្រព័ន្ធ**

| អង្គភាពសេដ្ឋកិច្ច ឬ សហគ្រាស តាមចំនួនអ្នកធ្វើការ | ភាគរយ (នៃចំនួនតាមប្រភេទនីមួយៗ) | |
|---|---|---|
| | ២០១១ | ២០២២ |
| ១-៤ | ១,៩% | ៦,៥% |
| ៥-៩ | ១៤% | ៨៣,៧% |
| ១០-៩៩ | ៣៣,៥% | ៩៧,៣% |
| ច្រើនជាង១០០ | ៧៨,៨% | ១០០% |

*ប្រភព: ជំរឿនសេដ្ឋកិច្ច ឆ្នាំ២០១១និង២០២២*

តារាងទី២ខាងក្រោមបង្ហាញថា អង្គភាពសេដ្ឋកិច្ចភាគច្រើន ស្ថិតនៅក្នុងវិស័យចំនួន៤រួមមាន វិស័យកម្មន្តសាល លក់ដុំ លក់រាយនិងជួសជុស សេវាកម្មស្នាក់នៅនិងអាហារ និងសេវាកម្មផ្សេងទៀត។ ក្នុងនោះ អង្គភាពសេដ្ឋកិច្ចនៅក្នុងវិស័យលក់ដុំ លក់រាយនិងជួសជុស សេវាកម្មស្នាក់នៅនិងអាហារ និងសេវាកម្មផ្សេងទៀត ភាគច្រើនគឺជាសហគ្រាសធុនមីក្រូ ដែលមានចំនួនអ្នកធ្វើការជាមធ្យមប្រហែល២នាក់ ប៉ុន្តែវិស័យសេវាកម្មស្នាក់នៅនិងអាហារ ក៏មានសហគ្រាសធុនតូចនិងមធ្យមច្រើនដែរ ជាពិសេសនៅក្នុងប្រព័ន្ធ ដែលមានចំនួនអ្នកធ្វើការជាមធ្យមប្រហែល១០នាក់។ ដោយឡែក អង្គភាពសេដ្ឋកិច្ចក្នុងវិស័យកម្មន្តសាល មានចំនួនអ្នកធ្វើការជាមធ្យមរហូតដល់ទៅ២០នាក់។ តារាងទី២បង្ហាញថា <u>វិស័យនេះមានចំនួនសិប្បកម្មតូចៗច្រើន ដែលស្ថិតនៅក្រៅប្រព័ន្ធ ខណៈដែលអង្គភាពសេដ្ឋកិច្ចដែលនៅក្នុងប្រព័ន្ធ គឺជារោងចក្រធំៗ ដែលមានចំនួនអ្នកធ្វើការជាមធ្យម១២១នាក់</u>។

### តារាងទី២: សហគ្រាសក្រៅប្រព័ន្ធនិងក្នុងប្រព័ន្ធ តាមវិស័យ។

| វិស័យ | អង្គភាពសេដ្ឋកិច្ច/សហគ្រាស | | ចំនួនអ្នកធ្វើការមធ្យម | |
|---|---|---|---|---|
| | ចំនួនសរុប | ក្នុងប្រព័ន្ធ (ភាគរយ) | ក្នុងវិស័យទាំងមូល | ក្នុងប្រព័ន្ធ |
| លក់ដុំ លក់រាយនិងជួសជុលយានយន្ត | ៤៩៩ ៧៣១ | ៧,៥% | ១,៩ | ៥,៤ |
| សេវាកម្មស្នាក់នៅនិងអាហារ | ៩៦ ៣១៥ | ១២,២% | ២,៨ | ១០,៥ |
| កម្មន្តសាល | ៥៤ ៨៧១ | ១៥,៦% | ២០,៣ | ១២១,២ |
| សេវាកម្មផ្សេងទៀត | ៥៣ ៣៩១ | ១៤,២% | ២,២ | ៥,៦ |

*ប្រភព: ជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២*

ជារួម ស្រដៀងគ្នានឹងការងារក្រៅប្រព័ន្ធ ទំហំនៃអង្គភាពសេដ្ឋកិច្ចឬសហគ្រាសដែលនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា មានការធ្លាក់ចុះ ប៉ុន្តែការធ្លាក់ចុះនៅតែមានសម្ទុះយឺត។ ការណ៍នេះបណ្តាលមកពីកម្រិតទាបនៃការធ្វើអន្តរកាលរបស់សហគ្រាសធុនមីក្រូនិងតូច(MSEs) ដែលភាគច្រើនស្ថិតក្នុងវិស័យលក់ដុំ លក់រាយ និងជួសជុស សេវាកម្មស្នាក់នៅនិងអាហារ សេវាកម្មផ្សេងទៀត និងសិប្បកម្ម។

# ផ្នែកទី ៤
# បញ្ហាប្រឈមនិងកិច្ចអន្តរាគមន៍

## ៤.១- បញ្ហាប្រឈម

សេដ្ឋកិច្ចក្រៅប្រព័ន្ធមានការពាក់ព័ន្ធនឹងតួអង្គច្រើន ទាំងក្នុងវិស័យសាធារណៈ និងឯកជន ដោយតួអង្គពាក់ព័ន្ធនីមួយៗជួបប្រទះនឹងបញ្ហាប្រឈមផ្សេងៗគ្នា។ ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធទាមទារឱ្យមានការស្វែងយល់ពីបញ្ហាប្រឈម ដើម្បីអាចកំណត់ដំណោះស្រាយសមស្រប។ យោងតាមរបាយការណ៍នៃការសិក្សា និងការពិគ្រោះយោបល់របស់សមាគម អង្គការជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍ និងក្រសួង ស្ថាប័នពាក់ព័ន្ធការជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ នឹងជួបប្រទះនឹងបញ្ហាប្រឈមចម្បងៗដូចខាងក្រោម៖

### ៤.១.១- ការកំណត់និយមន័យមិនទាន់ច្បាស់លាស់និងទិន្នន័យមិនពេញលេញ

សេដ្ឋកិច្ចក្រៅប្រព័ន្ធ មានវិសាលភាពធំ និងទាមទារឱ្យមាននិយមន័យជាក់លាក់ដើម្បីបែងចែកឱ្យបានច្បាស់លាស់រវាងសេដ្ឋកិច្ចក្រៅប្រព័ន្ធនិងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ បច្ចុប្បន្ន កម្ពុជាមិនទាន់មាននិយមន័យជាក់លាក់នៅឡើយ ដែលការណ៍នេះបង្កការលំបាកដល់ការកំណត់វិសាលភាព ការធានាសង្គតិភាពរវាងក្រសួង ស្ថាប័ន និងការដាក់ចេញនូវវិធានការអន្តរាគមន៍ឱ្យចំគោលដៅនិងប្រកបដោយប្រសិទ្ធភាព។ ស្របពេលជាមួយគ្នានេះ កម្ពុជាក៏ជួបប្រទះនឹងបញ្ហាកង្វះទិន្នន័យពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលបង្កការលំបាកដល់ការស្វែងយល់ឱ្យបានគ្រប់ជ្រុងជ្រោយ។ ជាមួយគ្នានេះដែរ ការសិក្សាអំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានចំនួនច្រើន ប៉ុន្តែការសិក្សាទាំងនោះមានលក្ខណៈដាច់ដោយឡែកពីគ្នា និងប្រើប្រាស់និយមន័យផ្សេងៗគ្នា ដោយសារទំហំដ៏ធំនិងលក្ខណៈពហុវិស័យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

### ៤.១.២- កង្វះការយល់ដឹងនិងការផ្សព្វផ្សាយ

ភាគច្រើននៃអ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនដឹងឬមិនយល់ច្បាស់អំពីការគាំពារនិងគាំទ្រផ្សេងៗរបស់រាជរដ្ឋាភិបាល ក៏ដូចជាកាតព្វកិច្ចនិងអត្ថប្រយោជន៍នៃការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ និយោជកជាច្រើនបានបញ្ជាក់ថា មានបំណងចង់បំពេញអនុលោមភាពឱ្យបានត្រឹមត្រូវ ប៉ុន្តែមិនដឹងថា ត្រូវចាប់ផ្ដើមពីណា ហើយត្រូវបំពេញនីតិវិធីអ្វីខ្លះ។ និយោជិតជាច្រើនក៏មិនដឹងថាខ្លួនមានសិទ្ធិ

ក្នុងការទទួលបានការគាំពារអ្វីខ្លះពីរាជរដ្ឋាភិបាល។ ជុំវិញបញ្ហានេះ វិស័យឯកជនក៏ដូចជាអង្គការជាតិនិងអន្តរជាតិ តែងស្នើសុំឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយនិងចំគោលដៅ អំពីនីតិវិធីនៃការចុះបញ្ជីទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អត្ថប្រយោជន៍នៃការចុះបញ្ជី និងការផ្តល់ការគាំទ្រនិងការលើកទឹកចិត្តនិងអត្ថប្រយោជន៍ផ្សេងៗ។

### ៤.១.៣- ការបំពេញអនុលោមភាព មានភាពស្មុគស្មាញនិងត្រូវការចំណាយខ្ពស់

នីតិវិធីស្មុគស្មាញ និងបន្ទុកចំណាយខ្ពស់ ទាំងពេលវេលានិងថវិកា បង្កឱ្យមានការលំបាកដល់ការបំពេញអនុលោមភាពផ្សេងៗ ជាពិសេសសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម(MSMEs) ដែលមានលទ្ធភាពទាប។ វិស័យឯកជនតែងលើកឡើងអំពីភាពត្រួតស៊ីគ្នា និងភាពមិនច្បាស់លាស់នៃការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្ត ដោយមានការចុះត្រួតពិនិត្យពីសំណាក់ក្រសួង ស្ថាប័នច្រើនផ្សេងគ្នា ដោយមិនមានការផ្សព្វផ្សាយ ឬជូនដំណឹងជាមុន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ បញ្ហាទាំងនេះបង្កឱ្យមានភាពមិនអាចប៉ាន់ប្រមាណបាននិងការព្រួយបារម្ភ ដែលធ្វើឱ្យទំនុកចិត្តក្នុងការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ធ្លាក់ចុះ។ ទន្ទឹមនេះ សហគ្រាសដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅតែអាចធ្វើប្រតិបត្តិការបានធម្មតា ដែលការណ៍នេះបង្កើតឱ្យមានការប្រកួតប្រជែងមិនស្មើភាពរវាងសហគ្រាសដែលនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាសដែលនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

### ៤.១.៤- លទ្ធភាពរបស់ប្រជាជននៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានកម្រិតទាប

ដូចបានបញ្ជាក់នៅក្នុងផ្នែកទី៣ខាងលើ អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជួបប្រទះនឹងបញ្ហាជីវភាពខ្វះខាត និងមិនអាចរ៉ាប់រងបន្ទុកចំណាយលើការបំពេញអនុលោមភាព។ ជាងនេះទៅទៀត អ្នកទាំងនេះក៏ងាយទទួលរងហានិភ័យពីវិបត្តិ ដូចជាវិបត្តិនៃជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យប្រជាជនជាច្រើនបាត់បង់ប្រាក់ចំណូល និងធ្លាក់ចូលទៅក្នុងភាពក្រីក្រ។

### ៤.១.៥- កង្វះយន្តការក្នុងការគ្រប់គ្រងនិងគាំទ្រដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ

អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានតម្រូវការខ្ពស់ផ្នែកថែទាំសុខភាព ប៉ុន្តែការផ្តល់ការថែទាំសុខភាពតាមរយៈបណ្តុំមូលនិធិសមធម៌សុខាភិបាល និងបណ្ណប.ស.ស. នៅមិនទាន់មានវិសាលភាពគ្របដណ្តប់និងការប្រើប្រាស់បានទូលំទូលាយនៅឡើយ។ ស្របពេលជាមួយគ្នានេះ អ្នកប្រកបមុខរបរនិងធ្វើការងារ

នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមួយចំនួនធំ មិនទាន់ស្ថិតក្រោមការគ្រប់គ្រងនិងការទទួលស្គាល់ដោយយន្តការនៃក្រសួង ស្ថាប័នណាមួយនៅឡើយ។ ជាក់ស្តែង អ្នកប្រកបមុខរបរនិងធ្វើការងារដោយមិនមានទីតាំងជាក់លាក់ មិនអាចស្នើសុំលិខិតអនុញ្ញាតផ្សេងៗពីយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួង ស្ថាប័នណាមួយនៅឡើយ។ ជាមួយគ្នានេះ បុគ្គលស្វ័យនិយោជន៍ ក៏នៅមិនទាន់អាចចូលជាសមាជិក ប.ស.ស. បាន ដោយសារកង្វះបទដ្ឋានគតិយុត្ត ជាពិសេសអនុក្រឹត្យនិងប្រកាសពាក់ព័ន្ធព្រមទាំងយន្តការគាំទ្រផ្សេងៗ បើទោះបីជាច្បាប់ស្តីពីរបបសន្តិសុខសង្គមចែងថាបុគ្គលស្វ័យនិយោជន៍អាចចូលរួមក្នុងផ្នែកថែទាំសុខភាពនិងប្រាក់សោធន តាមគោលការណ៍ស្ម័គ្រចិត្ត ក៏ដោយ។

### ៤.១.៦- គុណភាពនៃសេវាសាធារណៈនិងការគាំទ្រផ្សេងៗរបស់រាជរដ្ឋាភិបាលនៅមានកម្រិត

សេវាសាធារណៈនិងការគាំទ្រផ្សេងៗរបស់រាជរដ្ឋាភិបាល គឺជាភាពទាក់ទាញដ៏ចម្បង (ដូចជា សេវាសុខាភិបាល ការបណ្តុះបណ្តាល និងការលើកទឹកចិត្តផ្នែកពន្ធដារជាដើម) ដែលអាចលើកកម្ពស់ការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធផង និងលើកកម្ពស់សមត្ថភាពនិងផលិតភាពរបស់វិស័យឯកជនផង។ ទោះជាយ៉ាងនេះក្តី វិស័យឯកជនតែងលើកឡើងអំពីកង្វះការគាំទ្រក្នុងការពង្រីកអាជីវកម្ម ការទទួលបានហិរញ្ញប្បទាន និងការស្វែងរកទីផ្សារនិងកម្មករជំនាញ ព្រមទាំងការលំបាកក្នុងការទទួលបានសេវាសាធារណៈនិងការគាំទ្រផ្សេងៗដែលមានស្រាប់ ដោយសារគុណភាពនៃការផ្តល់សេវានិងលក្ខខណ្ឌតម្រូវច្រើន ដែលវិស័យឯកជនមិនអាចបំពេញបាន។

## ៤.២- កិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលបានដាក់ចេញនិងអនុវត្តនូវកម្មវិធីកែទម្រង់ជាច្រើន ដែលអាចប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ការគិតគូរក្នុងការរៀបចំយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ កម្មវិធីកែទម្រង់សំខាន់ៗ ដែលផ្តល់បច្ច័យវិជ្ជមាន ដោយផ្ទាល់និងដោយប្រយោលដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ មានដូចខាងក្រោម៖

### ៤.២.១- ការរៀបចំការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

ការចុះបញ្ជីអាជីវកម្មនៅកម្ពុជាជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន ដូចជាការបំពេញនីតិវិធីនៅក្រសួង ស្ថាប័នច្រើន និងដាច់ដោយឡែកពីគ្នា ដែលត្រូវប្រើពេលវេលា

យូរនិងចំណាយខ្ពស់។ ក្នុងគោលដៅសម្រួលនិងលើកទឹកចិត្តដល់ការចុះបញ្ជីអាជីវកម្ម រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការនូវដំណាក់កាលទី១ នៃថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange ឬហៅកាត់ថា ថ្នាលCamDX) នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ដែលអនុញ្ញាតឱ្យសហគ្រាសអាចធ្វើការចុះបញ្ជីអាជីវកម្មជាមួយក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងពេលតែមួយ តាមប្រព័ន្ធអនឡាញទាំងស្រុង ជាមួយនឹងនីតិវិធីងាយស្រួលនិងរហ័ស តម្រូវការព័ត៌មាននិងឯកសារតិច ព្រមទាំងថ្លៃសេវាទាបជាងមុន។ គិតត្រឹមខែសីហា ឆ្នាំ២០២៣ សហគ្រាសដែលបានធ្វើការចុះបញ្ជីអាជីវកម្ម តាមថ្នាលCamDX មានចំនួនជាង ២៨ ០០០ និងមានដើមទុនចុះបញ្ជីសរុបជាង៨ប៊ីលានដុល្លារអាមេរិក។

រាជរដ្ឋាភិបាលក៏បានដាក់ឱ្យដំណើរការដំណាក់កាលទី២ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ និងដំណាក់កាលទី៣ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ដោយបានដាក់បញ្ចូលទៅក្នុងថ្នាលCamDX នូវការស្នើសុំអាជ្ញាបណ្ណនិង/ឬលិខិតអនុញ្ញាតពីក្រសួងស្ថាប័នពាក់ព័ន្ធ នៅក្នុងវិស័យសំខាន់ៗ ដូចជាទេសចរណ៍ កម្មន្តសាល កសិកម្ម ប្រៃសណីយ៍និងទូរគមនាគមន៍ និងហិរញ្ញវត្ថុ ជាដើម។ រាជរដ្ឋាភិបាល បាននិងកំពុងរៀបចំដំណាក់កាលបន្តបន្ទាប់ទៀត ដើម្បីបន្តពង្រឹងការធ្វើសមាហរណកម្មរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងការសម្រួលដល់ដំណើរការនៃការចុះបញ្ជីសហគ្រាស ក៏ដូចជាកម្មករនិយោជិត ឱ្យបានជាអតិបរមា។

### ៤.២.២- ការលើកទឹកចិត្តផ្នែកពន្ធដារ

ក្នុងគោលបំណងលើកកម្ពស់បរិយាកាសធុរកិច្ចកម្ពុជា ជាពិសេសសម្រាលបន្ទុករបស់សហគ្រាស រាជរដ្ឋាភិបាលបានដាក់ចេញនូវការលើកទឹកចិត្តផ្នែកពន្ធដារ ជាបន្តបន្ទាប់ សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម ដូចជាការសម្រេចលុបចោលនូវពន្ធលើរបបម៉ៅការ សម្រាប់សហគ្រាសធុនមីក្រូ និង ការលើកលែងឬអនុគ្រោះពន្ធប្រថាប់ត្រាលើលិខិតស្តីពីការបង្កើតសហគ្រាស និងការកាត់បន្ថយពន្ធប៉ាតង់ ៥០% សម្រាប់ឆ្នាំដំបូងនៃការចុះបញ្ជីអាជីវកម្មរបស់សហគ្រាសធុនតូច មធ្យម និងធំ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏បានរៀបចំការចុះបញ្ជីដោយស្ម័គ្រចិត្ត ព្រមទាំងការលើកទឹកចិត្តផ្នែកពន្ធដារ ដល់សហគ្រាសធុនតូចនិងមធ្យម ដោយទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល ចាប់ពី៣ទៅ៥ឆ្នាំ ចំពោះវិស័យអាទិភាពមួយចំនួន ដូចជាផលិតផលកសិកម្មឬកសិឧស្សាហកម្ម

ផលិតនិងកែច្នៃម្ហូបអាហារ កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុក កែច្នៃកាកសំណល់និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍ ជាដើម។

### ៤.២.៣- អត្ថប្រយោជន៍គាំពារសង្គម

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យដំណើរការនូវកម្មវិធីជំនួយសង្គមជាច្រើន ដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយ និងរក្សាលំនឹងជីវភាពរបស់គ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យក្នុងស្ថានការណ៍ដ៏លំបាក ក្រោមរូបភាពផ្សេងៗ (ដូចជាវិធានការជំនួយសង្គមក្នុងកំឡុងពេលនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩) ព្រមទាំងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ និងជួយគាំទ្រដល់ប្រជាជនតាមជនបទនិងកសិករ។ ទន្ទឹមនេះរាជរដ្ឋាភិបាលក៏បានដាក់ឱ្យដំណើរការនូវរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារនិងផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយមានប.ស.ស. ជាប្រតិបត្តិករសន្តិសុខសង្គម។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏បានផ្តល់ការថែទាំសុខភាពដោយឥតគិតថ្លៃ តាមរយៈមូលនិធិសមធម៌សុខាភិបាល ជូនក្រុមអាទិភាព ដូចជាកម្មករក្រៅប្រព័ន្ធ បុគ្គលិកបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ អ្នកជាក់ស៊ីក្លូ កីឡាករជម្រើសជាតិ សមាជិកក្រុមប្រឹក្សាភូមិឃុំ និងក្រុមគ្រួសារជនពលីមរណៈ។

### ៤.២.៤- ការបណ្តុះបណ្តាលជំនាញ

ការអភិវឌ្ឍសមត្ថភាពកម្លាំងពលកម្ម ឱ្យក្លាយជាពលករដែលមានជំនាញ និងអាចមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាកម្រិតខ្ពស់ តាមរយៈការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាកត្តាគន្លឹះមួយដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានរៀបចំវគ្គបណ្តុះបណ្តាលជំនាញជាច្រើន ដូចជាការបណ្តុះបណ្តាលស្ពានចម្លងបន្តជំនាញ ការបណ្តុះបណ្តាលដើម្បីកាត់បន្ថយភាពក្រីក្រ តាមរយៈមូលនិធិជាតិ ការបណ្តុះបណ្តាលជំនាញសហគ្រិនជូនកម្មករ កម្មការិនី ការហ្វឹកហ្វឺនកូនជាងនៅតាមបណ្តាសហគ្រាសផ្សេងៗកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាហារូបករណ៍ដល់យុវជនក្រីក្រ និងការបណ្តុះបណ្តាលសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត១ សម្រាប់កម្មករ និយោជិត ដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩។

### ៤.២.៥- ការរៀបចំយន្តការធ្វើអធិការកិច្ចរួម

ក្នុងគោលបំណងកាត់បន្ថយបន្ទុកនិងការរំខានដល់រោងចក្រ សហគ្រាស ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម តាមរយៈគេហទំព័រ https://sicms.mlvt.gov.kh កាលពីខែមករា ឆ្នាំ២០២២។ ម្ចាស់ឬនាយករោងចក្រ សហគ្រាស មានកាតព្វកិច្ចធ្វើស្វ័យប្រកាសអធិការកិច្ចការងារ ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចំនួន២លើកក្នុងមួយឆ្នាំ ដែលធ្វើឡើងរៀងរាល់៦ខែម្តង។ ការធ្វើអធិការកិច្ចការងារ ត្រូវធ្វើឡើងរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដោយរាជរដ្ឋាភិបាលបានបង្កើតក្រុមអធិការកិច្ចអន្តរក្រសួងចំនួន៣ តាមរយៈប្រកាសអន្តរក្រសួង ក្នុងវិស័យកម្មន្តសាល វិស័យឧស្សាហកម្មទេសចរណ៍ និងវិស័យកសិកម្ម ដោយក្រុមអធិការកិច្ចអន្តរក្រសួងនីមួយៗត្រូវធ្វើអធិការកិច្ចរួមគ្នាក្នុងពេលតែមួយ និងតែមួយលើកប៉ុណ្ណោះក្នុងមួយឆ្នាំ។

## ផ្នែកទី៥
## អាទិភាពជាយុទ្ធសាស្ត្រ

ដើម្បីដោះស្រាយបញ្ហាប្រឈម និងឈានឆ្ពោះទៅសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ព្រមទាំងធានាប្រសិទ្ធភាពនិងភាពសមស្របនឹងបរិបទកម្ពុជា យុទ្ធសាស្ត្រជាតិនេះត្រូវបានរៀបចំឡើងដោយផ្អែកលើការសិក្សាពីឧត្តមានុវត្តន៍ជាតិនិងអន្តរជាតិ ការពិគ្រោះយោបល់ផ្ទាល់ជាមួយប្រជាជនគោលដៅនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងតំណាងសមាគម អង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍ និងបានកំណត់អាទិភាពជាយុទ្ធសាស្ត្រចំនួន៥ រួមមាន៖

**ទី១** ការកំណត់ ការកែសម្រួល និងការរៀបចំយន្តការបង្កលក្ខណៈងាយស្រួលដើម្បីឈានចូលក្នុងប្រព័ន្ធ។

**ទី២** ការកាត់បន្ថយបន្ទុកលើការបំពេញអនុលោមភាព។

**ទី៣** ការផ្តល់ការគាំពារនិងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ។

**ទី៤** ការលើកកម្ពស់សមត្ថភាព និងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ ឱ្យរីកធំធាត់ ដើម្បីអាចចូលរួមពេញលេញក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

**ទី៥** ការពង្រឹងនិងពង្រីកការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងអត្ថប្រយោជន៍នៃការឈានចូលក្នុងប្រព័ន្ធ ក៏ដូចជាការលើកកម្ពស់ការចូលរួមរបស់គ្រប់តួអង្គពាក់ព័ន្ធ។

សម្រាប់អាទិភាពជាយុទ្ធសាស្ត្រនីមួយៗ នឹងមានការដាក់ចេញនូវវិធានការកែទម្រង់មុតស្រួច ដែលអាចចែកចេញជា៣ផ្នែកសំខាន់ៗ គឺ: (១) វិធានការរយៈពេលខ្លី ដែលត្រូវសម្រេចឱ្យបាននៅក្នុងឆ្នាំ២០២៣-២០២៤(Low-Hanging Fruits) (២) វិធានការរយៈពេលមធ្យម (ឆ្នាំ២០២៥-២០២៦) និង (៣) វិធានការរយៈពេលវែង (ឆ្នាំ២០២៧-២០២៨)។

**រូបភាពទី២: គំនូសបំព្រួញនៃអាទិភាពជាយុទ្ធសាស្ត្រជាតិ**



## ៥.១- ការកំណត់ ការកែសម្រួល និងការរៀបចំយន្តការបង្កលក្ខណៈងាយស្រួល ដើម្បីឈានចូលក្នុងប្រព័ន្ធ

ការលើកកម្ពស់ការឈានចូលទៅក្នុងប្រព័ន្ធ ទាមទារឱ្យមានការកំណត់និយមន័យ និងវិសាលភាពនៃយន្តការគ្រប់គ្រង ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល ដើម្បីបែងចែកឱ្យបានច្បាស់លាស់រវាងសេដ្ឋកិច្ចក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបែងចែកសេដ្ឋកិច្ចជាពតំបន់សំខាន់ៗ ដែលរួមមាន: **តំបន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ តំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** និង **តំបន់នៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ** (មានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធទី២នៃយុទ្ធសាស្ត្រជាតិនេះ)។ ដោយអ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានលទ្ធភាពទាបនិងមិនអាចរ៉ាប់រងចំណាយលើការបំពេញបែបបទចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធបាន កម្ពុជាមានភាពចាំបាច់ក្នុងការបង្កើតតំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីបង្កលក្ខណៈងាយស្រួលដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្នុងការឈានចូលក្នុងប្រព័ន្ធអភិវឌ្ឍន៍អន្តរកាលមួយ ដោយមិនមានការបង់កម្រៃសេវានានា ដើម្បីទទួលបានអត្ថប្រយោជន៍និងការថែបំប៉នឱ្យរីកធំធាត់មុននឹងអាចមានលទ្ធភាពចូលរួមបានពេញលេញ ទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

ស្របតាមការបែងចែងតំបន់ខាងលើ យន្តការនៃការឈានចូលក្នុងប្រព័ន្ធនៅកម្ពុជា មានការពាក់ព័ន្ធនឹងក្រសួង ស្ថាប័នច្រើន និងដាច់ដោយឡែកពីគ្នា។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នឹងពង្រឹងយន្តការគ្រប់គ្រងនិងការធ្វើសមាហរណកម្មរវាងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីធានាសង្គតិភាពនិងភាពច្បាស់លាស់ តាមរយៈការជំរុញការប្រើប្រាស់ថ្នាលCamDX និងការកែសម្រួលនីតិវិធីនិងកាត់បន្ថយចំណាយ ទាំងពេលវេលានិងថវិកា ឱ្យបានជាអតិបរមា ក្នុងគោលដៅបើកផ្លូវឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងអស់អាចធ្វើអន្តរកាលចូលទៅក្នុងប្រព័ន្ធ បានដោយរលូន ងាយស្រួល រហ័ស និងចំណាយតិច (Smooth and Convenient Transition)។

## ៥.២- ការកាត់បន្ថយបន្ទុកលើការបំពេញអនុលោមភាព

បន្ថែមលើភាពរលូននិងភាពងាយស្រួលនៃការធ្វើអន្តរកាល រាជរដ្ឋាភិបាលក៏នឹងយកចិត្តទុកដាក់លើ **«ចីរភាពនៃការធ្វើអន្តរកាល»** (Sustainable Transition) ដោយធានាឱ្យបានថា សហគ្រាស កម្មករ និយោជិត និងបុគ្គលស្វ័យនិយោជន៍ ដែលបានចូលទៅក្នុងឬស្ថិតនៅក្នុងប្រព័ន្ធ អាចបន្តបំពេញអនុលោមភាព និងមិនវិលត្រឡប់ទៅរកសេដ្ឋកិច្ច

ក្រៅប្រព័ន្ធវិញ។ រាជរដ្ឋាភិបាលនឹងកាត់បន្ថយបន្ទុកលើការបំពេញអនុលោមភាពឱ្យបានជាអតិបរមា និងបញ្ចៀសការបង្កើតបទដ្ឋានគតិយុត្តតឹកតាប់ ដែលបង្កឱ្យមានការលំបាក ជាពិសេសសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម(MSMEs) ដែលមានលទ្ធភាពទាប ទាំងថវិកា ទាំងចំណេះដឹង ក្នុងការស្វែងយល់និងការបំពេញនីតិវិធីផ្សេងៗ។ រាជរដ្ឋាភិបាលក៏នឹងធានាឱ្យបាននូវភាពអាចប៉ាន់ប្រមាណបាន ពិសេសជុំវិញការផាកពិន័យផ្សេងៗ ដែលជាកត្តាបង្កឱ្យមានការរារែកក្នុងការធ្វើអន្តរកាលចូលទៅក្នុងប្រព័ន្ធ។ ជាក់ស្តែង រាជរដ្ឋាភិបាលនឹងផ្តល់ការលើកលែងការបង់កម្រៃសេវាផ្សេងៗ និងលើកលែងការផាកពិន័យទាំងអស់ក្នុងពេលវេលាកំណត់ជាក់លាក់មួយ ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមក ដើម្បីបើកផ្លូវឱ្យសហគ្រាសនិងកម្មករ និយោជិតដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ អាចធ្វើអន្តរកាលនិងចាប់ផ្តើមអាជីវកម្មថ្មីនៅក្នុងប្រព័ន្ធ ដោយមិនមានការព្រួយបារម្ភ។

## ៥.៣- ការផ្តល់ការគាំពារនិងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ

ដើម្បីធានាចីរភាពនៃការធ្វើអន្តរកាល រាជរដ្ឋាភិបាលនឹងពង្រីកនិងពង្រឹងវិសាលភាពនៃមូលនិធិសមធម៌សុខាភិបាល ព្រមទាំងផ្តល់ការគាំទ្រផ្នែកសុវត្ថិភាពការងារ ដើម្បីផ្តល់ការថែទាំសុខភាព ទៅដល់ក្រុមអាទិភាពនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ការផ្តល់កិច្ចគាំពារសង្គមនេះ សំដៅធានាផ្តល់នូវការគាំពារសុខភាព ដល់ក្រុមអាទិភាព ដើម្បីឱ្យមានលទ្ធភាពនិងអាចរស់នៅក្នុងកម្រិតជីវភាពមួយសមរម្យក្នុងប្រព័ន្ធ និងមិនធ្លាក់ចូលទៅក្នុងភាពក្រីក្រ ឬទទួលរងហានិភ័យខាងជីវភាពដោយគ្មានការយកចិត្តទុកដាក់។

ការពង្រីកនិងពង្រឹងវិសាលភាពនេះ នឹងអាចសម្រេចទៅបានយ៉ាងឆាប់រហ័ស និងមិនបង្កើនចំណាយបន្ថែមខ្ពស់ឡើយ ដោយក្រុមអាទិភាពមួយចំនួនត្រូវបានកំណត់អត្តសញ្ញាណជាគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដោយក្រសួងផែនការ ហើយគ្រួសារទាំងនេះក៏បាននិងកំពុងគ្របដណ្តប់ ដោយកម្មវិធីជំនួយសង្គមដែលមានស្រាប់។ ទោះជាយ៉ាងណាក្តី ដើម្បីបញ្ចៀសភាពត្រួតស៊ីគ្នានៃកម្មវិធីផ្សេងគ្នា និងធានាថាការពង្រីកវិសាលភាពនៃមូលនិធិសមធម៌សុខាភិបាល អាចទៅដល់ក្រុមប្រជាជនអាទិភាព ក៏ដូចជាក្រុមគោលដៅផ្សេងទៀតបាន ប្រកបដោយប្រសិទ្ធភាព ការពង្រីកនិងពង្រឹងវិសាលភាពត្រូវធ្វើឡើងជាជំហានៗ និងត្រូវមានការរៀបចំយន្តការកំណត់និងផ្ទៀងផ្ទាត់អត្តសញ្ញាណច្បាស់លាស់ ដោយមានលិខិតយោងដែលចេញដោយក្រសួង ស្ថាប័នជំនាញ ឬអាជ្ញាធរ

មូលដ្ឋាន សម្រាប់ក្រុមអាទិភាព ដែលមិនអាចស្នើសុំលិខិតយោងពីក្រសួង ស្ថាប័នជំនាញណាមួយ ក៏ដូចជាតាមដានជាប្រចាំនូវការចូលរួមទទួលយកផលប្រយោជន៍ពីកម្មវិធីទាំងនេះ។

## ៥.៤- ការលើកកម្ពស់សមត្ថភាពនិងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ

ដើម្បីឈានទៅសម្រេចចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយចីរភាព បរិយាបន្នភាពរឹងមាំ និង ភាពធន់ កម្ពុជាត្រូវការជានាឱ្យបាននូវ **«ប្រសិទ្ធភាពនៃការធ្វើអន្តរកាល»** (Efficient Transition) តាមរយៈការលើកកម្ពស់គុណភាពនិងភាពងាយស្រួលក្នុងការទទួលបានសេវាសាធារណៈ និងការគាំទ្រផ្សេងៗរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅជំរុញឱ្យអ្នកដែលបានឈានចូលក្នុងប្រព័ន្ធ រីកធំធាត់និងអាចចូលរួមពេញលេញក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់សមត្ថភាពនិងផលិតភាពនិងផ្តល់ការគាំទ្រដល់សកម្មភាពក្នុងប្រព័ន្ធ ជាពិសេសការដាក់ចេញនូវកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេក ទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេសដែលត្រូវបានកំណត់អត្តសញ្ញាណដោយក្រសួងផែនការ ក៏ដូចជាក្រុមគោលដៅមកពីសេដ្ឋកិច្ចក្រៅប្រព័ន្ធដទៃទៀត។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏នឹងលើកកម្ពស់ការទទួលបានហិរញ្ញប្បទានពីធនាគាររដ្ឋនិងឯកជន ព្រមទាំងលើកកម្ពស់បរិយាបន្ននិងចំណេះដឹងហិរញ្ញវត្ថុ ដើម្បីផ្តល់លទ្ធភាពឱ្យកាន់តែទូលំទូលាយដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក៏ដូចជាបុគ្គលស្វ័យនិយោជន៍ ក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងចៀសវាងការប្រើប្រាស់មិនចំគោលដៅ ដែលបង្កើនជាហានិភ័យបំណុលលើសលប់។

អត្ថប្រយោជន៍ទាំងនេះ នឹងក្លាយជាកត្តាទាក់ទាញយ៉ាងសំខាន់ សម្រាប់ការធ្វើអន្តរកាលចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ក៏ដូចជាការបង្កើនថ្លៃដើមកាលានុវត្តភាព (Opportunity Costs) នៃសកម្មភាពនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ៥.៥- ការពង្រឹងនិងពង្រីកការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងនិងការចូលរួម

ដូចបានរៀបរាប់នៅក្នុងផ្នែកទី៤ខាងលើ កង្វះការយល់ដឹងនិងការផ្សព្វផ្សាយ គឺជាបញ្ហាប្រឈមមួយក្នុងការជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល

នឹងធ្វើសកម្មភាពឱ្យកាន់តែសកម្ម ក្នុងការទាក់ទាញសហគ្រាស កម្មករ និយោជិត និងបុគ្គលស្វ័យនិយោជន៍ដែលស្ថិតនៅក្នុងក្រុមឬវិស័យអាទិភាពក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យចូលរួមទៅក្នុងប្រព័ន្ធ តាមរយៈការពង្រីកនិងពង្រឹងប្រសិទ្ធភាពនៃការផ្សព្វផ្សាយនិងការលើកកម្ពស់ការយល់ដឹង អំពីគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងអត្ថប្រយោជន៍នៃការឈានចូលក្នុងប្រព័ន្ធ។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលក៏នឹងលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន ដៃគូអភិវឌ្ឍ និងសមាគមឬអង្គការផ្សេងៗ ដែលមានការប្រមូលផ្តុំនិងធ្វើសកម្មភាពផ្ទាល់ច្រើនជាមួយអ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយមានការជំរុញការរៀបចំសម្ព័ន្ធសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីលើកកម្ពស់កិច្ចសន្ទនា និងការចូលរួមក្នុងការរៀបចំគោលនយោបាយផ្សេងៗ។

## ផ្នែកទី៦
## ការគ្រប់គ្រងហានិភ័យ

ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាកិច្ចការដែលមានភាពស្មុគស្មាញ និងទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធ។ ភាពខ្វះខាតក្នុងទិដ្ឋភាពណាមួយអាចចោទជាហានិភ័យដល់ប្រសិទ្ធភាព និងបន្ទច់បង្អាក់ ឬធ្វើឱ្យរាំងស្ទះដល់ការអនុវត្ត **យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨**។ ក្នុងស្មារតីនេះ កម្ពុជាត្រូវមានភាពបុរេសកម្មនិងត្រូវធ្វើការវិភាគអំពីហានិភ័យ និងកំណត់បញ្ហាគំរាមកំហែងនានា ដែលអាចប៉ះពាល់ដល់ការអនុវត្តយុទ្ធសាស្ត្រជាតិនេះ ដើម្បីកំណត់វិធានការបង្ការនិងការពារ តាមការចាំបាច់។ ចំពោះមុខ ហានិភ័យធំៗមានចំនួន៣ ដូចខាងក្រោម៖

- **ហានិភ័យផ្នែកសារពើពន្ធ:** ជាមួយនឹងទំហំដ៏ធំនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការផ្តល់ការគាំពារ និងគាំទ្រ បូករួមទាំងការកាត់បន្ថយបន្ទុកចំណាយ ទាំងថ្លៃសេវានិងប្រាក់ពន្ធ ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមក្នុងប្រព័ន្ធ អាចបង្កឱ្យមានហានិភ័យដល់លម្ហសារពើពន្ធ (Fiscal Space) ទាំងផ្នែកចំណាយ និងចំណូល ស្របពេលដែលរាជរដ្ឋាភិបាលត្រូវការជាចាំបាច់នូវធនធានក្នុងបរិបទតំបន់និងសកល នាពេលបច្ចុប្បន្ន។ រាជរដ្ឋាភិបាលនឹងមានភាពម៉ឺងម៉ាត់ក្នុងការអនុវត្តនិងបញ្ចៀសឱ្យបាននូវការរីកធំឡើងៗនៃការផ្តល់ការគាំពារ ដោយជំនួសមកវិញនូវការយកចិត្តទុកដាក់លើការអភិវឌ្ឍ

សេដ្ឋកិច្ច ក្រោមគោលការណ៍ **«មិនបង្រៀនឱ្យប្រជាជនរស់នៅដោយពឹងផ្អែកលើរដ្ឋ»**។

- **លទ្ធភាពក្នុងការទាញយកអត្ថប្រយោជន៍ ពីការគាំពារនិងការគាំទ្ររបស់រាជរដ្ឋាភិបាល:** ផ្អែក លើធនធានថវិកា សមត្ថភាព ឬចំណេះដឹង ព័ត៌មានបណ្តាញ ឬទីតាំងអំណោយផលរបស់ប្រជាជនផ្ទាល់។ ការដាក់ចេញនូវវិធានការអន្តរាគមន៍ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ អាចមិនទៅដល់ប្រជាជនដែលនៅឆ្ងាយនិងងាយរងគ្រោះបំផុត។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាល នឹងធានាឱ្យបាននូវតម្លាភាពនិងសមធម៌ ជាពិសេសតាមរយៈការចូលរួមយ៉ាងសកម្មពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅគ្រប់លំដាប់ថ្នាក់ ដើម្បីធានាវិសាលភាពគ្របដណ្តប់នៃការគាំទ្រឱ្យបានជាអតិបរមា។
- **ការកើតឡើងនៃប្រភេទការងារនិងអាជីវកម្មថ្មីៗ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ:** រាល់ព្រឹត្តិការណ៍ដែលប៉ះពាល់ដល់រចនាសម្ព័ន្ធសេដ្ឋកិច្ច ទោះវិជ្ជមានឬអវិជ្ជមាន តែងបង្កើតឡើងនូវសកម្មភាពសេដ្ឋកិច្ចថ្មីៗ ឬពង្រីកបន្ថែមនូវសកម្មភាពសេដ្ឋកិច្ច ដែលមានស្រាប់។ វិបត្តិនៃជំងឺកូវីដ-១៩ បានជំរុញឱ្យមានការកើនឡើងយ៉ាងគំហុកនូវសកម្មភាពថ្មីៗ ជាពិសេសការលេចចេញនូវប្រភេទការងារនិងអាជីវកម្មដែលគ្មានទីតាំងជាក់លាក់ ដែលអាចចាត់ចូលទៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយក្របខ័ណ្ឌគតិយុត្តនិងយន្តការដែលមានស្រាប់ ផ្តោតសំខាន់លើការគ្រប់គ្រងប្រភេទការងារនិងអាជីវកម្មដែលមានទីតាំងជាក់លាក់។ ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកលបាននិងកំពុងតែវិវត្តកាន់តែលឿន ដោយសារឌីជីថលភាវូបនីយកម្ម បរិវត្តកម្មឌីជីថល និងការប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចសកល ប្រភេទការងារនិងអាជីវកម្មថ្មីជាច្រើន អាចនឹងកើតមានឡើងហួសពីការរំពឹងទុក និងការប៉ាន់ប្រមាណបាន ដែលការណ៍នេះទាមទារឱ្យមានការតាមដានជាប្រចាំលើការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចជាតិ តំបន់ និងសកល ដើម្បីត្រៀមខ្លួន ឱ្យបានកាន់តែប្រសើរក្នុងការគាំទ្រនិងស្រូបយកប្រភេទការងារនិងអាជីវកម្មថ្មីៗចូលក្នុងប្រព័ន្ធ។

# ផ្នែកទី៧
# យន្តការស្ថាប័ន និងការតាមដាននិងវាយតម្លៃ

ការអនុវត្ត **យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨** គឺជាអាទិភាពដ៏សំខាន់និងចម្បងមួយរបស់រាជរដ្ឋាភិបាល ដែលនឹងចូលរួមកំណត់ទិសដៅរួមនិងគន្លងនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់ តាមរយៈការជំរុញការចូលរួមនិងលើកកម្ពស់សក្តានុពលសេដ្ឋកិច្ចកម្ពុជាឱ្យបានជាអតិបរមា។ ការអនុវត្តប្រកបដោយប្រសិទ្ធភាព ត្រូវមានការប្តេជ្ញានិងការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាល ដោយមានការរៀបចំយន្តការអនុវត្ត តាមដាននិងវាយតម្លៃឱ្យបានជាប់លាប់ ម៉ត់ចត់ ល្អិតល្អន់ និងច្បាស់លាស់ ព្រមទាំងការកែលម្អនិងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់ ដើម្បីរក្សាឯកសារយុទ្ធសាស្ត្រជាតិនេះ ជា **«ឯកសាររស់»** ឱ្យស្របតាមការវិវត្តនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ការអនុវត្តយុទ្ធសាស្ត្រជាតិ ព្រមទាំងការគ្រប់គ្រងហានិភ័យដែលអាចកើតមានឡើង ត្រូវមានការចូលរួមយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់ ពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធគ្រប់កម្រិត ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ **ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្តយុទ្ធសាស្ត្រជាតិ** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពលម្អិត ក៏ដូចជារៀបចំផែនការថវិកាសម្រាប់អនុវត្តរាល់វិធានការ ដែលត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រជាតិនេះ
- ផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តនិងបញ្ហាប្រឈម ទៅដល់ស្ថាប័នបង្គោល (ដូចមានកំណត់ខាងក្រោម) ដោយមានការបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់ សម្រាប់វិធានការ ដែលមានវឌ្ឍនភាពយឺត
- ផ្តល់កិច្ចសហការដល់ស្ថាប័នបង្គោល តាមរយៈការផ្តល់ទិន្នន័យឱ្យបានគ្រប់គ្រាន់និងគ្រប់ជ្រុងជ្រោយ សម្រាប់ការតាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិ
- កំណត់ថ្នាក់ដឹកនាំនិងមន្ត្រីបង្គោលឱ្យបានច្បាស់លាស់ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្ត និងការសម្របសម្រួលជាមួយស្ថាប័នបង្គោល និង
- ចូលរួមកែសម្រួលឬរៀបចំឯកសារយុទ្ធសាស្ត្រឬគោលនយោបាយ ក្នុងដំណាក់កាលបន្តបន្ទាប់ទៀត។

ជាមួយគ្នានេះ **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ឧ.វ.ប.ន.)** ត្រូវដើរតួនាទីជាស្ថាប័នបង្គោលរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអនុវត្តយុទ្ធសាស្ត្រជាតិ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព និងមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំក្របខ័ណ្ឌតាមដាននិងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រជាតិ ដោយមានកំណត់សូចនាករគន្លឹះ ដែលអាចវាស់វែងបាន ក៏ដូចជាវិធានការគន្លឹះ និងកំណត់យន្តការច្បាស់លាស់ ក្នុងការជំរុញនិងពន្លឿនការអនុវត្តវិធានការដែលមានវឌ្ឍនភាពយឺត និងការចាត់វិធានការចំពោះវិធានការដែលមិនមានវឌ្ឍនភាព
- រៀបចំរបាយការណ៍វាយតម្លៃរយៈពេលខ្លី ពាក់កណ្តាលអាណត្តិ និងចុងអាណត្តិនៃការអនុវត្តយុទ្ធសាស្ត្រជាតិ គោរពជូន **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** អំពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រជាតិ
- ដឹកនាំការកែសម្រួលឬការរៀបចំឯកសារយុទ្ធសាស្ត្រ ឬគោលនយោបាយក្នុងដំណាក់កាលបន្តបន្ទាប់ទៀត តាមតម្រូវការចាំបាច់ ដោយត្រូវដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង
- សម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ទាំងក្នុងវិស័យសាធារណៈនិងឯកជន ព្រមទាំងស្ថាប័ន ជាតិនិងអន្តរជាតិ ដើម្បីតាមដានការវិវត្តនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងប្រមូលធាតុចូលសម្រាប់ការធ្វើការកែលម្អ និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ តាមការចាំបាច់។

## ផ្នែកទី៨
## សេចក្តីសន្និដ្ឋាន

វិបត្តិនៃជំងឺកូវីដ-១៩ ព្រមទាំងបញ្ហាប្រឈមសកលផ្សេងទៀត បានដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរមកលើជីវភាពរស់នៅរបស់ប្រជាជន ពិសេសអ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ជាការឆ្លើយតប បណ្តាប្រទេសក្នុងតំបន់និងលើសកលលោកបានបង្កើនការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗលើការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយកំណត់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធជាកាតាលីករយ៉ាងសំខាន់ ក្នុងការរួមចំណែកសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់ទៅនឹងវិបត្តិ។

ស្របតាមនិន្នាការតំបន់និងសកល ព្រមទាំងផ្អែកតាមអនុសាសន៍របស់ស្ថាប័នអន្តរជាតិ ជាពិសេស ទស្សនវិស័យប្រែក្លាយវិបត្តិឱ្យទៅជាកាលានុវត្តភាពរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ការរៀបចំនិងដាក់ចេញនូវ «**យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨**» គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវ ដោយឯកសារនេះជាប្រទីបមួយយ៉ាងសំខាន់ ដែលនឹងជួយបំភ្លឺនិងត្រួសត្រាយផ្លូវនៅលើគន្លងមួយដែលពោរពេញទៅដោយភាពស្មុគស្មាញ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ ក៏នឹងក្លាយជាកាតាលីករដែលនឹងជួយជំរុញនិងលើកទឹកចិត្តឱ្យបង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន អង្គការជាតិនិងអន្តរជាតិ និងសមាគមនានា ដែលបាននិងកំពុងខិតខំលើកស្ទួយសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយផ្ទាល់ឬដោយប្រយោល តាមសមត្ថកិច្ចរៀងខ្លួន និងដាច់ដោយឡែកពីគ្នា។ បន្ថែមលើនេះ ការអនុវត្តយុទ្ធសាស្ត្រជាតិនេះ ក៏នឹងក្លាយជាទុនយ៉ាងសំខាន់សម្រាប់កម្ពុជាក្នុងការតម្រង់ទិសការអភិវឌ្ឍសង្គម សេដ្ឋកិច្ចតាមរយៈការផ្តល់ជាធាតុចូលនិងបទពិសោធន៍សំខាន់និងថ្មីៗ សម្រាប់ការគិតគូររៀបចំឯកសារយុទ្ធសាស្ត្រ ឬគោលនយោបាយផ្សេងទៀតទៅអនាគត សំដៅឈានឆ្ពោះទៅរកការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់យ៉ាងពិតប្រាកដស្របតាមគោលការណ៍ «**មិនបោះបង់ពលរដ្ឋខ្មែរណាម្នាក់**» ទាំងក្នុងន័យអភិវឌ្ឍ និងការចូលរួមក្នុងដំណើរការនៃការអភិវឌ្ឍ។

# ឧបសម្ព័ន្ធទី១
# ការកំណត់វិសាលភាពនិងការធ្វើអាទិភាពូបនីយកម្ម

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តស្របតាមអភិក្រមនៃយុទ្ធសាស្ត្រជាតិនេះ ក្នុងដំហានដំបូងនៃការអនុវត្ត រាជរដ្ឋាភិបាលកំណត់វិស័យនិងប្រភេទអាជីវកម្ម មុខរបរ និងការងារអាទិភាព ដូចក្នុងតារាងខាងក្រោម ដោយនឹងមានការតាមដានឱ្យបានជាប់លាប់ នូវការវិវត្តនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការពិនិត្យឡើងវិញជាទៀតទាត់ អំពីភាពចាំបាច់ក្នុងការពង្រីកឬពង្រួមវិសាលភាពនេះ។

### តារាងទី៣: វិស័យនិងប្រភេទអាជីវកម្ម មុខរបរ និងការងារអាទិភាព

| តួអង្គ | អាទិភាព |
|---|---|
| សហគ្រាស | លក់ដុំ លក់រាយ និងជួសជុស |
| | សេវាកម្មស្នាក់នៅនិងអាហារ |
| | សិប្បកម្ម |
| | សហគមន៍កសិកម្ម |
| អ្នកប្រកបអាជីវកម្ម និងធ្វើការងារ | កម្មករសំណង់ |
| | អ្នកបម្រើសេវាភេសជ្ជៈ កម្សាន្ត និងម៉ាស្សា |
| | អ្នកកែសម្ផស្ស សាឡន និងជាងកាត់សក់ |
| | អ្នករត់ម៉ូតូឌុប ម៉ូតូកង់បី អ្នករត់ម៉ូតូដឹកទំនិញ និងអ្នករត់តាក់ស៊ី |
| | អាជីវករលក់តាមផ្សារ |
| | សិល្បករ |
| | កីឡាករ |
| | អ្នកសារព័ត៌មាន |
| | អាជីវករចល័តតាមដងផ្លូវ |
| | អ្នកបម្រើសេវាតាមរោងការ |
| | ពលករក្នុងវិស័យកសិកម្ម |

**សំគាល់៖**

- ស្របតាមគោលដៅនិងអាទិភាពជាយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រជាតិនេះ សហគ្រាស និងអ្នកប្រកបអាជីវកម្មនិងធ្វើការងារ ដែលត្រូវបានកំណត់នៅក្នុងតារាងទី៣ ខាងលើ នឹងអាចទទួលបានអត្ថប្រយោជន៍ផ្សេងៗ ប៉ុន្តែការផ្តល់អត្ថប្រយោជន៍ត្រូវមានការកំណត់លក្ខណវិនិច្ឆ័យនិងការវាយតម្លៃឱ្យបានត្រឹមត្រូវ។
- តារាងទី៣ខាងលើ ត្រូវចាត់ទុកជា **«បញ្ជីរស់»** ដែលអាចធ្វើបច្ចុប្បន្នកម្មបាន ដើម្បីពង្រីកឬពង្រួមវិសាលភាព ប៉ុន្តែការធ្វើបច្ចុប្បន្នកម្ម ត្រូវមានការកំណត់លក្ខណវិនិច្ឆ័យនិងការវាយតម្លៃឱ្យបានត្រឹមត្រូវ ជាពិសេសលើទិដ្ឋភាពថវិកា។

# ឧបសម្ព័ន្ធទី២
# ការកំណត់និយមន័យ

ក្នុងន័យជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប្រកបដោយប្រសិទ្ធភាពខ្ពស់ យុទ្ធសាស្ត្រជាតិនេះ នឹងបែងចែកសេដ្ឋកិច្ចជា៣តំបន់ ដូចខាងក្រោម៖

**ទី១ តំបន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ:** សេដ្ឋកិច្ចក្រៅប្រព័ន្ធ(Informal Economy) សំដៅដល់គ្រប់សកម្មភាពអាជីវកម្ម មុខរបរ និងការងារ ដែល (១) មិនមែនជាសកម្មភាពខុសច្បាប់ និង(២) មិនមានការបំពេញបែបបទរដ្ឋបាល ដែលនាំឱ្យមានការលំបាកក្នុងការកំណត់អត្តសញ្ញាណ។

**ទី២ តំបន់នៃការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ:** លទ្ធភាពរបស់អ្នកប្រកបមុខរបរ និងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានកម្រិតនិងមិនអាចបំពេញបែបបទពេញលេញ ដើម្បីចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធបាន ដូច្នេះ ត្រូវមានការបង្កើតតំបន់នេះឡើង ដោយមានការតម្រូវឱ្យមានការបំពេញបែបបទរដ្ឋបាលគោលខ្លះ តែមិនមានការបង់កម្រៃសេវា ដើម្បីងាយស្រួលក្នុងការកំណត់អត្តសញ្ញាណ ហើយទទួលបាននូវការថែបំប៉ន និងអត្ថប្រយោជន៍ផ្សេងៗ ដើម្បីឈានចូលទៅក្នុងតំបន់នៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

**ទី៣ តំបន់នៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ:** សកម្មភាពនៅក្នុងតំបន់នេះ មានលក្ខណៈ២ដែរគឺ (១) មិនមែនជាសកម្មភាពខុសច្បាប់ និង(២) បំពេញបែបបទរដ្ឋបាលបានពេញលេញ ដែលងាយស្រួលកំណត់អត្តសញ្ញាណ។ បែបបទរដ្ឋបាលពេញលេញ មានបង្ហាញក្នុងតារាងខាងក្រោម៖

| តួអង្គពាក់ព័ន្ធ | នីតិវិធីរដ្ឋបាល |
|---|---|
| សហគ្រាសធុនតូច មធ្យម និងធំ | ក្រសួងពាណិជ្ជកម្ម, អ.ព.ដ., ក.ក.ប. និងក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត |
| សហគ្រាសធុនមីក្រូ | យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ, អ.ព.ដ. និងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| កម្មករ និយោជិត | មន្ទីរ/ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប.ស.ស. |
| បុគ្គលស្វ័យនិយោជន៍ | យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និង ប.ស.ស. |

**សំគាល់៖**

- យោងតាមច្បាប់ស្តីពីការងារ **កម្មករ និយោជិត** សំដៅដល់ជនគ្រប់ភេទនិងគ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យាធ្វើការយកកម្រៃ ក្រោមការដឹកនាំនិងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គលឬនីតិបុគ្គលជាសាធារណៈ ឬឯកជន។
- យោងតាមច្បាប់ស្តីពីការងារ **សហគ្រាស**ត្រូវបានបង្កើតឡើងដោយនិយោជកដែលជារូបវន្តបុគ្គលឬនីតិបុគ្គល ដោយមានប្រើប្រាស់កម្មករ និយោជិតម្នាក់ឬច្រើននាក់ ទោះបីមិនបានជាប់លាប់ក៏ដោយ។ ការបែងចែកទំហំនៃសហគ្រាសជាសហគ្រាសធុនមីក្រូ តូច មធ្យម ឬធំ ត្រូវស្របតាមលក្ខខណ្ឌកំណត់នៅក្នុងសេចក្តីជូនដំណឹងលេខ៣៦ សជណ.ហធ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីលទ្ធផលកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម លើកទី២។
- យោងតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម **បុគ្គលស្វ័យនិយោជន៍** សំដៅដល់ជនដែលប្រកបការងារឬមុខរបររកចំណូលផ្ទាល់ខ្លួន ដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួលឬប្រាក់បៀវត្ស ដែលផ្តល់ដោយនិយោជកឬរដ្ឋ តាមកិច្ចសន្យាការងារ ហើយក៏មិនមានប្រើប្រាស់កម្មករ និយោជិត នៅក្នុងសកម្មភាពការងារឬមុខរបររបស់ខ្លួន។

## ឧបសម្ព័ន្ធទី៣

## តារាងផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨

| ល.រ. | វិធានការគន្លឹះ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
|---|---|---|---|
| **I. ការកំណត់ ការកែសម្រួល និងការរៀបចំយន្តការបង្កលក្ខណៈងាយស្រួល ដើម្បីឈានចូលក្នុងប្រព័ន្ធ** | | | |
| ១ | តាមដានការវិវត្តនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការពិនិត្យឡើងវិញអំពីភាពចាំបាច់ក្នុងការពង្រីកឬពង្រួមវិស័យនិងប្រភេទអាជីវកម្ម មុខរបរ និងការងារអាទិភាព ដែលត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃយុទ្ធសាស្ត្រជាតិនេះ | - ក.ឱ.វ.ប.ន. | ២០២៣-២០២៤ |
| ២ | រៀបចំអនុក្រឹត្យ ដើម្បីកំណត់អំពីគោលការណ៍ អត្រាភាគទាន លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចុះបញ្ជិកានៅប.ស.ស. ផ្នែកថែទាំសុខភាព សម្រាប់បុគ្គលស្វ័យនិយោជន៍ | - ក.ក.ប.<br>- ប.ស.ស. | ២០២៣-២០២៤ |
| ៣ | ផ្ទៀងផ្ទាត់ព័ត៌មានសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីអាជីវកម្មរួចរាល់លើថ្នាល CamDX ដើម្បីពង្រឹងអនុលោមភាពពាក់ព័ន្ធនឹងការចូលជាសមាជិកនៃប.ស.ស. | - ប.ស.ស.<br>- ក.ស.ហ.វ. | ២០២៣-២០២៤ |
| ៤ | រៀបចំការធ្វើសមាហរណកម្មប្រព័ន្ធចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន កម្មករ និយោជិត និងបុគ្គលស្វ័យនិយោជន៍របស់ប.ស.ស. ក្រោមប្រព័ន្ធរួមតែមួយរបស់ក.ក.ប. នៅលើថ្នាលCamDX ដោយអនុវត្តគោលការណ៍ «តែមួយលើក» (The Once-Only Principle) | - ក.ក.ប.<br>- ប.ស.ស.<br>- ក.ស.ហ.វ. | ២០២៥-២០២៦ |
| ៥ | រៀបចំបង្កើតមូលដ្ឋានទិន្នន័យ ស្តីពីការបង្កើតអាជីវកម្ម(National Business Registry Database) | - ក្រសួងពាណិជ្ជកម្ម<br>- ក.ស.ហ.វ. | ២០២៥-២០២៦ |

| | | | |
|---|---|---|---|
| | | - ក្រសួងផែនការ<br>- ក.ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | |
| ៦ | រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួម ដោយថ្លក់ភ្ជាប់ជាមួយនឹងថ្នាលCamDX សម្រាប់ការស្នើសុំបើកអាជីវកម្មផ្សេងៗ ក្នុងវិស័យអាទិភាព នៅថ្នាក់ក្រោមជាតិ ការចុះបញ្ជីពន្ធដារ និងការចុះបញ្ជិកានៅមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមទាំងប.ស.ស. ដោយមានការសម្រួលនីតិវិធីនិងកាត់បន្ថយបន្ទុកចំណាយ ទាំងពេលវេលានិងថវិកា | - ក្រសួងមហាផ្ទៃ<br>- ក្រសួងពាណិជ្ជកម្ម<br>- អ.ព.ជ. នៃ ក.ស.ហ.វ.<br>- ក.ក.ប.<br>- ប.ស.ស.<br>- ក.ឱ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៥-<br>២០២៦ |
| ៧ | រៀបចំទម្រង់បែបបទនិងនីតិវិធីបច្ចេកទេសនៃការផ្តល់សេវាជាកញ្ចប់ ឱ្យមានស្តង់ដាអនុវត្តរួមតែមួយ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការច្រកចេញចូលតែមួយ | - ក្រសួងមហាផ្ទៃ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៧-<br>២០២៨ |
| ៨ | ប្រមូលទិន្នន័យអំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យបានទៀងទាត់ ដោយមានការផ្ទៀងផ្ទាត់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធានាសុក្រឹតភាពនៃទិន្នន័យ សំដៅលើកកម្ពស់ការយល់ដឹង និងអាចធ្វើការកែសម្រួលឬដាក់ចេញនូវផែនការសកម្មភាពថ្មី | - ក្រសួងផែនការ<br>- ក.ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | រៀងរាល់<br>៣ឆ្នាំ |

| II. ការកាត់បន្ថយចំណាយលើការបំពេញអនុលោមភាព | | | |
|---|---|---|---|
| ១ | ផ្តល់ការលើកលែងការផាកពិន័យនិងបំណុលទាំងអស់ ក្នុងឆ្នាំ២០២៣-២០២៨ ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមក ដើម្បីបើកផ្លូវឱ្យសហគ្រាសដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចធ្វើអន្តរកាលនិងចាប់ផ្តើមអាជីវកម្មថ្មីនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដោយមិនមានការព្រួយបារម្ភ | - ក្រសួងពាណិជ្ជកម្ម<br>- ក.ក.ប.<br>- ក.ឧ.វ.ប.ន.<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ក.ស.ហ.វ.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៣-២០២៤ |
| ២ | ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនមីក្រូ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ២០២៣-២០២៨ ដោយលើកលែងកម្រៃសេវាចុះបញ្ជីពន្ធដារ និងកម្រៃសេវាធ្វើបច្ចុប្បន្នភាព | - អ.ព.ដ. នៃ ក.ស.ហ.វ. | ២០២៣-២០២៨ |
| ៣ | ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ២០២៣-២០២៨ តាមរយៈការលើកលែងពិន័យទោសទណ្ឌនិងបំណុលពន្ធ ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជី លើកលែងកម្រៃសេវាចុះបញ្ជីពន្ធដារនិងកម្រៃសេវាធ្វើបច្ចុប្បន្នភាពនៅពេលចុះបញ្ជី និងលើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនិងពន្ធអប្បបរមា សម្រាប់រយៈពេល២ឆ្នាំ ក្រោយការចុះបញ្ជី | - អ.ព.ដ. នៃ ក.ស.ហ.វ. | ២០២៣-២០២៨ |
| ៤ | ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនមធ្យម ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ២០២៤-២០២៥ តាមរយៈការលើកលែងពិន័យទោសទណ្ឌ និងបំណុលពន្ធ ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជី និង | - អ.ព.ដ. នៃ ក.ស.ហ.វ. | ២០២៤-២០២៥ |

| | | | |
|---|---|---|---|
| | លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនិងពន្ធអប្បបរមា សម្រាប់រយៈពេល២ឆ្នាំ ក្រោយការចុះបញ្ជី | | |
| ៥ | ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ២០២៤ឬឆ្នាំ២០២៥ តាមរយៈការលើកលែងការបង់ពន្ធប៉ាតង់ សម្រាប់រយៈពេល ២ឆ្នាំ បន្ទាប់ពីទទួលបានការសម្រេចឱ្យចុះបញ្ជី | - អ.ព.ដ. នៃ ក.ស.ហ.វ. | រយៈពេល ២ឆ្នាំ |
| ៦ | កាត់បន្ថយថ្លៃសេវាសម្រាប់ការផ្តល់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស និងការចុះបញ្ជិកាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន និងសៀវភៅបើកប្រាក់ខែសម្រាប់សហគ្រាសដែលមានចំនួនកម្មករ និយោជិតតិចជាង៨នាក់ | - ក.ក.ប. | ២០២៣-២០២៤ |
| ៧ | ពង្រឹងយន្តការស្វ័យត្រួតពិនិត្យ និងពង្រឹងការអនុវត្តយន្តការក្រុមអធិការកិច្ចអន្តរក្រសួង នៅថ្នាក់ជាតិ ដើម្បីធានាការចុះធ្វើអធិការកិច្ចរួមគ្នាក្នុងពេលតែមួយនិងមួយលើកក្នុងមួយឆ្នាំ | - ក.ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៣-២០២៤ |
| ៨ | រៀបចំការចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចរួមគ្នាក្នុងពេលតែមួយនិងតែមួយលើកក្នុងមួយឆ្នាំ នៅថ្នាក់ក្រោមជាតិ សម្រាប់គ្រប់សហគ្រាសដែលបានឬមិនទាន់បានចុះបញ្ជី ឬស្នើសុំអាជ្ញាបណ្ណឬលិខិតអនុញ្ញាតផ្សេងៗ | - រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ក្រសួងមហាផ្ទៃ | ២០២៣-២០២៤ |
| ៩ | រៀបចំបង្កើតបទដ្ឋានគតិយុត្ត ក្របខ័ណ្ឌ និងយន្តការដែលផ្តល់ស្ថានភាពស្របច្បាប់ (Legal Status) ជាសហគ្រាសធុនមីក្រូនិងតូច(MSEs) ដោយភ្ជាប់ជាមួយនឹងអត្ថប្រយោជន៍ផ្សេងៗ ដូចជាការលើកលែងការបង់ថ្លៃសេវារដ្ឋបាល នានា សម្រាប់រយៈពេល៥ឆ្នាំ ជាដើម | - ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- ក្រសួងពាណិជ្ជកម្ម<br>- អ.ព.ដ. នៃ ក.ស.ហ.វ.<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២៣-២០២៤ |

| | | | |
|---|---|---|---|
| | | - ក្រសួង ស្ថាប័នពាក់ព័ន្ធ | |
| **III. ការផ្តល់ការគាំពារនិងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ** | | | |
| ១ | ពង្រីកនិងពង្រឹងវិសាលភាពមូលនិធិសមធម៌សុខាភិបាល ជូនដល់គ្រួសារងាយរងហានិភ័យ និងក្រុមគោលដៅមកពីសេដ្ឋកិច្ចក្រៅប្រព័ន្ធដទៃទៀត | - ក្រុមប្រឹក្សាជាតិគាំពារសង្គម<br>- ក.ក.ប.<br>- ប.ស.ស.<br>- ក្រសួងសុខាភិបាល | ២០២៣-២០២៤ |
| ២ | ពង្រឹងយន្តការបើកផ្តល់គោលរបបឧបត្ថម្ភ នៅពេលសម្រាលកូន ដល់កម្មករ និយោជិតទាំងក្នុងនិងក្រៅប្រព័ន្ធ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុភូមិ និងជំនួយការភូមិជាស្ត្រី | - ក.ក.ប. | ២០២៣-២០២៤ |
| ៣ | ពង្រីកវិសាលភាពនៃការផ្តល់អត្ថប្រយោជន៍ផ្នែកថែទាំសុខភាព ទៅដល់អ្នកក្នុងបន្ទុក (Dependent) នៃសមាជិកប.ស.ស. | - ក្រុមប្រឹក្សាជាតិគាំពារសង្គម<br>- ប.ស.ស.<br>- ក្រសួងសុខាភិបាល | ២០២៣-២០២៤ |
| ៤ | បន្តជំរុញការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តនិងលក្ខខណ្ឌការងារ ស្របតាមស្ថានភាពនៃសហគ្រាសធុនមីក្រូ តូច និងមធ្យម និងស្របតាមការវិវត្តនៅក្នុងពិភពការងារ ជាពិសេសប្រភេទការងារពីចម្ងាយ និងតាមថ្នាលបច្ចេកវិទ្យា | - ក.ក.ប. | ២០២៥-២០២៦ |
| ៥ | រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងQR Code លើបណ្ណសមធម៌ និងបណ្ណ ប.ស.ស. ដែលអាចស្កេន ដើម្បីទទួលយកព័ត៌មានអត្តសញ្ញាណបុគ្គលនិងប្រវត្តិនៃការចូល | - ក្រុមប្រឹក្សាជាតិគាំពារសង្គម<br>- ក្រសួងសុខាភិបាល | ២០២៥-២០២៦ |

| | | | |
|---|---|---|---|
| | ព្យាបាល តាមរយៈការអភិវឌ្ឍ និងដាក់ឱ្យអនុវត្តប្រព័ន្ធកំណត់ត្រាវេជ្ជសាស្ត្រអេឡិចត្រូនិក( Electronic Medical Record-EMR ) | - ក្រសួងផែនការ<br>- ប.ស.ស. | |
| ៦ | ធានាសង្គតិភាព សុខដុមនីយកម្ម និងអន្តរប្រតិបត្តិការរវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលនិធិសមធម៌សុខាភិបាល ប.ស.ស. និងប្រព័ន្ធរបស់មូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន | - ក្រុមប្រឹក្សាជាតិគាំពារសង្គម<br>- ក្រសួងសុខាភិបាល<br>- ក្រសួងផែនការ<br>- ប.ស.ស. | ២០២៥-២០២៦ |
| ៧ | រៀបចំក្របខ័ណ្ឌវាយតម្លៃសមត្ថភាពមូលដ្ឋានសុខាភិបាលរដ្ឋនិងឯកជន ដើម្បីលើកកម្ពស់ការផ្តល់សេវាក្នុងប្រព័ន្ធថែទាំសុខភាពសង្គម | - ក្រុមប្រឹក្សាជាតិគាំពារសង្គម<br>- ក្រសួងសុខាភិបាល<br>- ប.ស.ស. | ២០២៥-២០២៦ |
| ៨ | សិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យដំណើរការរបបសោធនសម្រាប់ប្រជាជននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមិនចាត់ចូលក្នុងប្រជាជនក្រីក្រនិងងាយរងគ្រោះ រួមមានអាជីវករលក់ដូរ និងប្រជាជនដែលស្ថិតក្នុងស្វ័យកម្មភាព ជាដើម នៅក្រោមយន្តការដែលមានស្រាប់ ក្នុងគោលដៅផ្តល់នូវយន្តការការពារពេលចាស់ជរាជូនប្រជាជនគ្រប់រូប | - ក.ក.ប. | ២០២៥-២០២៦ |
| ៩ | សិក្សារៀបចំយន្តការចុះបញ្ជី និងបង្កើតក្របខ័ណ្ឌដែលផ្តល់ស្ថានភាពស្របច្បាប់ ជាអាជីវករចល័ត តាមដងផ្លូវ( Street Vendors ) ជាមួយនឹងអត្ថប្រយោជន៍ផ្សេងៗ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមពីការរៀបចំគម្រោងសាកល្បង( Pilot Project ) | - ក្រសួងមហាផ្ទៃ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៤-២០២៨ |

| IV. **ការលើកកម្ពស់សមត្ថភាព និងការគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ** | | | |
|---|---|---|---|
| ១ | ដាក់ចេញនិងជំរុញការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស នៅតាមបណ្តាគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនានារបស់រដ្ឋ ក្នុងកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈកម្រិត១(C1) | - ក្រុមប្រឹក្សាជាតិគាំពារសង្គម<br>- ក.ក.ប.<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៣-២០២៤ |
| ២ | រៀបចំកម្មវិធីលើកទឹកចិត្តដល់សហគ្រាសដែលបានចុះបញ្ជីចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ តាមរយៈការផ្តល់ការបណ្តុះបណ្តាលដល់កម្មករ និយោជិត ដោយប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ជំនាញនិងសហគ្រិនភាព | - ក.ស.ហ.វ. | ២០២៣-២០២៤ |
| ៣ | បង្កើតគម្រោងឥណទានទំហំតូចៗ ក្នុងធនាគារសហគ្រាសធុនតូចនិងមធ្យម និងធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម ដើម្បីឱ្យសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ដែលបានចុះបញ្ជីចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ អាចទទួលបានឥណទាន | - ធនាគារសហគ្រាសធុនតូច និង មធ្យម<br>- ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | ២០២៣-២០២៤ |
| ៤ | បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការរៀបចំនិង អនុវត្តការទទួលស្គាល់ការសិក្សាដែលមានពីមុន និងការទទួលស្គាល់សមត្ថភាពនាពេលបច្ចុប្បន្ន | - ក.ក.ប. | ២០២៣-២០២៤ |
| ៥ | លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ តាមរយៈការផ្សព្វផ្សាយសាធារណៈនិងការសិក្សាអប់រំទូទៅ | - ធនាគារជាតិនៃកម្ពុជា | ២០២៣-២០២៤ |
| ៦ | លើកទឹកចិត្តឱ្យបុគ្គលស្វ័យនិយោជន៍ សហគ្រាសធុនតូចនិងមធ្យម ឱ្យបើកគណនីសន្សំនិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ | - ធនាគារជាតិនៃកម្ពុជា | ២០២៥-២០២៦ |

| | | | |
|---|---|---|---|
| ៧ | អភិវឌ្ឍប្រព័ន្ធទូទាត់ដែលងាយស្រួលទទួលបាន ចំណាយតិច និងមានប្រសិទ្ធភាព ដើម្បីលើកកម្ពស់ដល់ការទទួលសេវាហិរញ្ញវត្ថុ | - ធនាគារជាតិនៃកម្ពុជា | ២០២៥-២០២៦ |
| ៨ | បង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ស្ត្រី | - ធនាគារជាតិនៃកម្ពុជា | ២០២៥-២០២៦ |
| ៩ | ពង្រីកកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ និងកម្មវិធីស្ពានចម្លងបន្តជំនាញ ដើម្បីផ្តល់លទ្ធភាពដល់សិស្សដែលបានបោះបង់ការសិក្សា និងកម្លាំងពលកម្មដែលកំពុងធ្វើការ ឱ្យបន្តការរៀនសូត្រក្នុងប្រព័ន្ធTVET | - ក.ក.ប. | ២០២៥-២០២៦ |
| ១០ | រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស សំដៅពលករជំនាញ ដើម្បីធ្វើការចល័តក្នុងតំបន់ | - ក.ក.ប. | ២០២៧-២០២៨ |
| ១១ | ពង្រឹងនិងពង្រីកវិសាលភាពនៃទីភ្នាក់ងារជាតិមុខរបរនិងការងារ | - ក.ក.ប. | ២០២៧-២០២៨ |
| **V. ការពង្រឹងនិងពង្រីកការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងនិងការចូលរួម** | | | |
| ១ | រៀបចំគេហទំព័រ ដើម្បីពន្យល់និងផ្សព្វផ្សាយអំពីគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងអត្ថប្រយោជន៍នៃការឈានចូលក្នុងប្រព័ន្ធ | - ក.ឧ.វ.ប.ន. | ២០២៣-២០២៤ |
| ២ | ពង្រីកនិងពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពនៃការផ្សព្វផ្សាយឱ្យបានទូលំទូលាយនិងចំគោលដៅ អំពីនីតិវិធីនៃការចុះបញ្ជីទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ចំណាយ និងអត្ថប្រយោជន៍នៃការចុះបញ្ជី និងកាតព្វកិច្ចបំពេញអនុលោមភាព ព្រមទាំងការគាំទ្រនិងលើកទឹកចិត្តផ្សេងៗ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងពាណិជ្ជកម្ម<br>- អ.ព.ដ. នៃ ក.ស.ហ.វ.<br>- ក.ក.ប. | ២០២៣-២០២៤ |

| | | | |
|---|---|---|---|
| ៣ | ជំរុញការចូលរួមរបស់សមាគម អង្គការជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍ និងជាពិសេសវិស័យឯកជន ក្នុងការជំរុញអ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ | - ប.ស.ស.<br>- ក.ឧ.វ.ប.ន.<br>- ក.ស.ហ.វ.<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៣-២០២៤ |
| ៤ | ទាក់ទាញការចូលរួមពីវិស័យដែលនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ជាពិសេសសហគ្រាសធុនធំ ឱ្យចូលរួមជួយគាំទ្រនិងរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ | - គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៣-២០២៤ |
| ៥ | លើកទឹកចិត្តឱ្យមានការរៀបចំយន្តការស្វ័យសម្របសម្រួល ដើម្បីធ្វើតំណាងឱ្យវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជំរុញការរៀបចំសម្ព័ន្ធសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីលើកកម្ពស់កិច្ចសន្ទនានិង ការចូលរួមរបស់អ្នកប្រកបមុខរបរ និងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្នុងការរៀបចំគោលនយោបាយផ្សេងៗ | - ក.ឧ.វ.ប.ន. | ២០២៣-២០២៤ |
| ៦ | បង្កើនសមត្ថភាពមន្ត្រីប.ស.ស. ដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការដឹកនាំនិងផ្តល់សេវា និងពង្រឹងយន្តការផ្តល់ព័ត៌មាន ដល់សាធារណជន | - ក.ក.ប.<br>- ប.ស.ស. | ២០២៣-២០២៤ |
| ៧ | លើកកម្ពស់ការទទួលបានព័ត៌មានអំពីការបង្កើតអាជីវកម្ម ជាពិសេសតាមរយៈការពង្រីកវិសាលភាព និងជំរុញការផ្សព្វផ្សាយតាមថ្នាលធុរកិច្ច business.gov.kh | - មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី តេជោ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០២៥-២០២៦ |
| ៨ | ស្រាវជ្រាវ វាយតម្លៃ និងផ្សព្វផ្សាយអំពីឥទ្ធិពលនៃការប្រែក្លាយសកម្មភាពធុរកិច្ចនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលកើតមានចំពោះការបង្កើតការងារ ប្រាក់ចំណូល និងផលិតភាព | - ក.ក.ប. | ២០២៥-២០២៦ |